# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*បើអស់លោកជាជនជាប់ចោទ សុខចិត្តធ្វើការស្ម័យទិតៀន អស់លោកនឹងឃើញច្បាស់នូវលទ្ធផលជាក់ស្តែងឥតប្រកែកបាន តាមរយៈភស្តុតាងរាប់មិនអស់ ដូចជា រណ្តៅរួមកប់ខ្មោច ដែលមានទូទាំងប្រទេស និងសក្ខីកម្មរបស់ជនរងគ្រោះរាប់មិនអស់ដែរនៃមហាឧក្រិដ្ឋកម្មរបស់អង្គការបដិវត្តន៍។*[1]

**- ដើមបណ្តឹងរដ្ឋប្បវេណី លោក ពិន យ៉ាថៃ**

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ

នៅសប្តាហ៍នេះ សវនាការជំនុំជម្រះ បានប្រព្រឹត្តឡើងត្រឹមតែពីរថ្ងៃប៉ុណ្ណោះ ដោយយោងទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ **នួន ជា**។ អង្គជំនុំជម្រះ បានប្រកាសថា ជនជាប់ចោទរូបនេះទើបតែចាកចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន ប៉ុន្តែត្រូវចូលសម្រាកមន្ទីរពេទ្យជាថ្មីម្តងទៀតនៅថ្ងៃសៅរ៍បន្ទាប់។ ដូច្នេះ កិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ ត្រូវលើកឡើងនូវបញ្ហាទាំងឡាយណា ដែលមិនទាក់ទងនឹងសំណុំរឿងរបស់គាត់ ឬប្រធានបទជាក់លាក់ផ្សេងៗ ដែលគាត់បានលះបង់សិទ្ធិរបស់គាត់នៅក្នុងការចូលរួមតាមដាន មានដូចជា៖ ការបន្តធ្វើបទឧទ្ទេសលើតួនាទីរបស់ជនជាប់ចោទ **ខៀវ សំផន** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2] និងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក **ពិន យ៉ាថៃ**។

ឯកសារដែលបានបង្ហាញកាលពីថ្ងៃអង្គារ បានផ្តល់ជាតម្រុយបន្ថែមស្តីពីការសិក្សាមនោគមវិជ្ជារបស់លោក **ខៀវ សំផន** ការចូលរួមរបស់គាត់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងកម្រិតនៃតួនាទីរបស់គាត់ ហើយនិងការយល់ដឹងនៃគោលនយោបាយកសិកម្មមហន្តរាយនៃរបបនេះ ការបោសសម្អាត និងការសម្លាប់រង្គាល។ នៅថ្ងៃព្រហស្បតិ៍ លោក **ពិន យ៉ាថៃ** បានឡើងសវនាការ ហើយបានផ្តល់សក្ខីកម្មពីបទពិសោធន៍របស់គាត់ជុំវិញការជម្លៀសដំណាក់កាលទីមួយ និងទីពីរ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រធិបតេយ្យ មុនពេលដែលគាត់បានរត់គេចខ្លួនទៅប្រទេសថៃ នៅឆ្នាំ១៩៧៧។

## ផ្នែកទី២ ៖ សក្ខីកម្មសង្ខេបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

លោក **ពិន យ៉ាថៃ** បានកើតនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៤។ នៅចុងឆ្នាំ១៩៧៩ គាត់បានសរសេរសៀវភៅមួយក្បាលដែលមានចំណងជើងថា **"មនោគមវិជ្ជា មហាឃាតក"** (**L'Utopie Meurtrière**) ដោយបានបោះពុម្ពជាភាសាបារាំង ហើយមានមួយក្បាលទៀត មានចំណងជើងថា **"ជីវិតកូនថ្លៃ កូនត្រូវតែរស់"** (**Stay Alive My Son**) នៅឆ្នាំ១៩៨៧[3]។ សៀវភៅទីពីរ ដែលបានក្លាយជាមូលដ្ឋានចម្បងសម្រាប់ការតាំងសំណួររបស់ភាគី គឺជាការបកស្រាយពីសៀវភៅទីមួយ ដោយមានបន្ថែមខ្លឹមសារដោយសមាជិកគ្រួសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ នៅក្នុងការផ្ដល់សក្ខីកម្មរបស់គាត់ លោក **ពិន យ៉ាថៃ** បានរ៉ាយរ៉ាប់ពីបទពិសោធន៍របស់គាត់នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីប្រជាជននៅដំណាក់កាលបន្ទាប់។ គាត់ក៏បានផ្ដល់សក្ខីកម្មផងដែរពីលក្ខខណ្ឌរស់នៅ និងស្ថានភាពនយោបាយមុនឆ្នាំ១៩៧៥ និងស្ថានភាពបន្ទាប់ពីការរត់គេចខ្លួនរបស់គាត់ទៅកាន់ប្រទេសថៃនៅឆ្នាំ១៩៧៧។ ទាក់ទងនឹងជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានពិពណ៌នាពីវិធីដែលខ្មែរក្រហមបានឲ្យរបបអង្គរ ហើយមិនមានការផ្គត់ផ្គង់ថ្នាំសង្កូវណាមួយដល់ប្រជាជនឡើយ ដូចដែលគាត់បានលើកឡើងថា៖ "អង្គការអត់មានត្រូវការពេទ្យ អង្គការកាន់ការតែពីរមុខទេ តាមមើលទៅ។ ទីមួយ ចែកស្បៀងអាហារឲ្យយើងហូប។ ទីពីរ ចាត់ចែងឲ្យយើងទៅធ្វើការ មានម៉ោងពេល។ ទីបី អាហ្នឹងនិយាយថែមមួយទៀតចុះ គឺអប់រំនយោបាយ" [4]។

### ក. មុនឆ្នាំ១៩៧៥

នៅឆ្នាំ១៩៦៥ បន្ទាប់ពីគាត់បានបញ្ចប់ការសិក្សានៅសាលាពហុបច្ចេកទេស នៅទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា លោក **ពិន យ៉ាថៃ** បានចូលបម្រើការងារនៅក្នុងក្រសួងសាធារណការក្នុងប្រទេសកម្ពុជា។ ក្រោយមកទៀត គាត់បានឡើងឋានៈ ហើយមានតំណែងជាប្រធាននាយកដ្ឋានការងារ និងសម្ភារៈថ្មី ដោយបានដឹកនាំកម្មករចំនួន ១០០០នាក់។ នេះ ជាតំណែងដែលគាត់បានទទួលនៅពេលដែលខ្មែរក្រហម បានក្ដោបក្ដាប់អំណាច។

លោក **ម៉ៃខល កាណាវ៉ាស** ដែលជាមេធាវីការពារក្ដីឲ្យជនជាប់ចោទ **នួន ជា** បានសួរដេញដោលទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ស្ដីពីបក្ខពួកនិយម និងអំពើពុករលួយ នៅក្នុងសម័យ **សីហនុ** ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាក្នុងសៀវភៅរបស់គាត់។ ដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ដល់សក្ខីកម្មថា គាត់បានជឿជាក់ថា មានអំណាច មានអំពើពុករលួយ ហើយរដ្ឋមិនបានមាន "អំណាចស្ថាប័ន" ក្នុងការគ្រប់គ្រងអំណាចរបស់បុគ្គលម្នាក់ៗឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានផ្ដល់សក្ខីកម្មថា ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលរស់នៅក្នុងទីក្រុងភ្នំពេញ ដើមឡើយបានអបអរសាទរចំពោះការដួលរំលំនៃរបប **សីហនុ** និងការងើបឡើងនៃរបប **លន់ នល់** ។ ប្រជាជនទាំងនោះ មិនសប្បាយចិត្តនឹងការកើនឡើងនៃអំពើពុករលួយ ក៏ដូចជាការឈ្លានពានរបស់ជនជាតិវៀតណាមនៅតាមព្រំដែនកម្ពុជា ដែលបណ្ដាលឲ្យសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកមកលើតំបន់ជនបទជាច្រើន។ យោងតាមសាក្សីរូបនេះ ការឈ្លានពានរបស់ជនជាតិវៀតណាមបណ្ដាលមកពី **សម្ដេចសីហនុ** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាសម្ងាត់ជាមួយនឹងវៀតណាមខាង

ជើង ដែលអនុញ្ញាតឲ្យកងទ័ពថ្មើរជើងវៀតណាមឆ្លងកាត់ទឹកដីភាគបូព៌ានៃប្រទេសកម្ពុជា ក្នុងការដឹកជញ្ជូនសព្វាវុធទៅឲ្យវៀតណាមខាងត្បូង។ ចលនានេះ បានធ្វើឲ្យអាប់អោនដល់អព្យាក្រឹតភាពរបស់កម្ពុជា។

ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានរៀបរាប់ម្តងរួមកហើយ បន្ទាប់ពីរដ្ឋប្រហារទម្លាក់ **សម្តេចសីហនុ** លោក **លន់ នល់** បានសន្យាថា គាត់នឹងលុបបំបាត់អំពើពុករលួយ និងបណ្តេញជនជាតិវៀតណាម។ នៅពេលនោះ **សម្តេចសីហនុ** បានធ្វើដំណើរទៅប៉េកាំង ហើយបានគាំទ្រខ្មែរក្រហម ដែលកាលពីដើមមកធ្លាប់ជាសត្រូវរបស់ទ្រង់។ ក៏ប៉ុន្តែ សង្គ្រាមបានផ្ទុះឡើងយ៉ាងកំរោលក្នុងអំឡុងពេលនៃរបប **លន់ នល់** បានបង្ខំឲ្យប្រជាជនដែលរស់នៅទីជនបទភៀសខ្លួនទៅកាន់ទីក្រុងភ្នំពេញ។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានផ្តល់នូវជំរំសម្រាប់ប្រជាជនដែលបានផ្លាស់ទី និងបានផ្តល់បាយដល់ពួកគេ។ នៅពេលដែលសង្គ្រាមនៅកំពុងបន្ត អង្ករបានក្សត់ទៅៗ ហើយមានគ្រួសារជាច្រើនបានចាប់ផ្តើមលាក់ទុកអង្ករដែលមាន។ លោក **ពិន យ៉ាថៃ** បានសរសេរក្នុងសៀវភៅរបស់គាត់ថា តួនាទីរបស់គាត់ជាប្រធាននាយកដ្ឋានការងារថ្មី និងសម្ភារៈ ក្នុងក្រសួងនេះ បានការពារគាត់ ហើយនិងក្រុមគ្រួសាររបស់គាត់ពីផលវិបាកនៃនយោបាយ និងសេដ្ឋកិច្ច ដោយបាននិយាយថា សង្គ្រាមស៊ីវិល បានកើតមានឡើងនៅប្រទេសនេះ។

ដូចអ្នកទីក្រុងដទៃទៀតដែរ នៅពេលនោះ លោក **ពិត យ៉ាថៃ** បានដឹងពីការផ្សព្វផ្សាយតាមវិទ្យុ និងអត្ថបទសារព័ត៌មានដែលថា កងទ័ពខ្មែរក្រហមកំពុងរុលទៅមុខ ដូច្នេះ គាត់បានដឹងថា ខ្មែរក្រហមនឹងមកដល់ទីក្រុងភ្នំពេញ ក្នុងពេលឆាប់ៗនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានពិពណ៌នាពីព័ត៌មាន និងពាក្យចចាមអារ៉ាមទាំងនេះដែលកំពុងសាយភាយក្នុងអំឡុងពេលមុននៃការមកដល់របស់ខ្មែរក្រហម ដោយពាក្យចចាមអារ៉ាមទាំងនេះបាននិយាយពី លោក **លន់ នល់** បានភៀសខ្លួនពីប្រទេសនៅថ្ងៃទី១ ខែមេសា ហើយបានអះអាង ឲ្យមានការឈប់បាញ់គ្នាបន្ទាប់ពីការមកដល់របស់ពួកខ្មែរក្រហម។ លោក **ពិត យ៉ាថៃ** បានឮថា នាយករដ្ឋមន្ត្រីនៅពេលនោះ គឺលោក **ឡុង បូរ៉េត** បានទៅប្រទេសថៃ ហើយចរចាជាមួយនឹងពួកខ្មែរក្រហម។ ដូច្នេះ ប្រជាជនបានគិតថានឹងមានការចរចាបង្កើតជា "របបមួយថ្មី... ហើយយើងសង្ឃឹមថានឹងបានចប់រឿងវិវាទហ្នឹង យើងក៏បានសុខសប្បាយដែរបាទ"[5]។

## ខ. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោក **ពិន យ៉ាថៃ** និងគ្រួសាររបស់គាត់ បានកំពុងរស់នៅជាមួយនឹងឪពុកម្តាយក្មេករបស់គាត់នៅឯទឹកល្អក់ ក្នុងទីក្រុងភ្នំពេញ។ នៅពេលព្រឹកព្រលឹមនៅថ្ងៃនោះ កងទ័ពដែលប្រដាប់ដោយអាវុធនៅជាយក្រុង បានចូលទៅកាន់ទីក្រុង។ បន្ទាប់មក គាត់ និងក្រុមគ្រួសាររបស់គាត់ បានសម្រេចចិត្តចាកចេញទៅ ហើយបានមកស្នាក់នៅក្នុងផ្ទះរបស់បងប្អូនជីដូនមួយរបស់គាត់នៅម្តុំផ្សារស៊ីឡឹបសិន។ គាត់បានបរិយាយពីស្ថានភាពនៅពេលនោះយ៉ាងនឹងធឹង។ ដំបូងឡើយ ទាហានខ្មែរក្រហមបានឆ្លងកាត់តាមដងវិថី ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ បានឈរជាជួរតាមបណ្តោយផ្លូវ ដើម្បីអបអរសាទរដល់ពួកខ្មែរក្រហមទាំងនោះ។ ក៏ប៉ុន្តែ លោក **ពិន យ៉ាថៃ** ក៏បានផ្តល់សក្ខីកម្មផងដែរថា នៅថ្ងៃដដែលនោះ គាត់បានឮស្នូរកាំភ្លើង ហើយភ្លាមៗបន្ទាប់នោះ បានឃើញសាកសពបុរសវ័យក្មេងម្នាក់។ គាត់បានឮថា បុរសម្នាក់ត្រូវគេបាញ់សម្លាប់ ដោយសារតែបុរសនោះ មានបំណងចង់វិលត្រឡប់ទៅផ្ទះដើម្បីយករបស់មួយចំនួនដែលបានទុកនៅក្នុងផ្ទះ។

លោក **ពិន យ៉ាថៃ** និងបងប្អូនជីដូនមួយប្រុសរបស់គាត់ បានកាន់វត្តឧណ្ណាលោម ដើម្បីជួបនឹងសម្តេចសង្ឃរាជ **ហួត តាត** ដែលត្រូវជាមារបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ គាត់ បានឃើញមនុស្សម្នានៅទីនោះ បានថ្វាយបង្គំគោរពព្រះសង្ឃ នៅពេលដែលពួកគេបានសាកសួររកព័ត៌មាន។ នៅក្នុងចំណោមពួកគេ មានឧត្តមសេនីយ៍របស់ **លន់ នល់** ពីរនាក់ ដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានស្គាល់ ម្នាក់ក្នុងចំណោមនោះ គឺលោក **ជឹម ជួន**។ សម្តេច **ហួត តាត** បានមានសង្ឃដីកាទៅកាន់ប្រជាជនទាំងអស់ ឲ្យទៅសាកសួរព័ត៌មានពីលោក **ចៅ សៅ** ដែលជាប្រធានគណបក្សប្រឆាំង និងលោកស្រី **ជួប សំឡុត** ជាប្រធានកាកបាទក្រហមកម្ពុជា។ លោកស្រី **ជួប សំឡុត** បានឲ្យយោបល់ថា ដើមបណ្តឹងរដ្ឋប្បវេណី គួរតែទៅកាន់សណ្ឋាគារលើភ្នំ ដែលត្រូវបានប្រកាសជាកន្លែងសម្រាប់ជនភៀសខ្លួន។ នៅពេលដំណាលគ្នានោះ មានការផ្សព្វផ្សាយតាមវិទ្យុឲ្យសូមហៅមន្ត្រីរដ្ឋការ និងទាហាន **លន់ នល់** មកជួបជុំគ្នានៅក្រសួងឃោសនាការ នៅម៉ោងបួនល្ងាច។ សម្តេច **ហួត តាត** បានបញ្ជូនអ្នកតំណាងរបស់លោក ឈ្មោះព្រះតេជគុណ **សូ ហាយ** ឲ្យទៅកាន់ទីជួបជុំនោះផងដែរ។ ព្រះតេជគុណ **សូ ហាយ** លោកបាននិមន្តត្រឡប់មកនៅម៉ោង ៦ល្ងាច ហើយបានសង្ឃដីការាយការណ៍ថា មានមន្ត្រី **លន់ នល់** ជាច្រើននាក់ រួមទាំងនាយករដ្ឋមន្ត្រី **ឡុង បូរ៉េត** បានចូលរួមក្នុងការប្រជុំគ្នានេះ។ អ្នកដែលបានដឹកនាំការប្រជុំនេះ តាមការសន្និដ្ឋានរបស់ព្រះអង្គ **សូ ហាយ** គឺជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមម្នាក់ បានពន្យល់ថា របបថ្មីនេះនឹងត្រូវការអ្នកទាំងអស់គ្នាដើម្បីកសាងប្រទេស។ តាមឲ្យដឹងមក ព្រះតេជគុណ **សូ ហាយ** បានបញ្ជាក់ថា តាមពិតមិនមានការជម្លៀសប្រជាជនបានកើតមានឡើងនោះឡើយ។ ព្រះអង្គ បានមានសង្ឃដីកាអះអាងថា នេះគឺជាពាក្យចចាមអារ៉ាមរបស់អាមេរិកាំង ដែលប្រើឧបាយកលក្នុងការបំបែកប្រជាជនឲ្យចេញពីគ្នា។ ក៏ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនបានជឿទេ ដោយសារតែគាត់បានឃើញប្រជាជនកំពុងចាកចេញពីទីក្រុង។

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានស្នាក់នៅក្នុងវត្តឧណ្ណាលោម រហូតដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ ១៩៧៥ នៅពេលដែលពួកគាត់បានទទួលបញ្ជាពីទាហានខ្មែរក្រហមឲ្យចាកចេញពីទីក្រុង ដោយសារតែអង្គការត្រូវការ "សម្អាតទីក្រុង" ហើយអាមេរិកាំង អាចនឹងទម្លាក់គ្រាប់បែក។ ពួកគាត់ ត្រូវបានគេប្រាប់ឲ្យនាំយករបស់របរបន្តិចបន្តួចមកជាមួយសម្រាប់រយៈពេលបីថ្ងៃប៉ុណ្ណោះ។ ចំពោះព្រះសង្ឃគង់នៅវត្តឧណ្ណាលោម លោក **ពិត យ៉ាថៃ** បានរៀបរាប់ថា ព្រះសង្ឃទាំងនោះក៏ត្រូវបានសុំឲ្យនិមន្តចេញផងដែរ ក៏ប៉ុន្តែសម្តេចសង្ឃ **ហួត តាត** បានបដិសេធមិនចេញ ពីព្រោះលោកបានគង់នៅទីនោះជាង៨០ឆ្នាំថ្វាយមកហើយ។ នៅពេលនោះ មានព្រះសង្ឃជាច្រើនអង្គ ក៏បានសម្រេចចិត្តគង់នៅជាមួយនឹងសម្តេចសង្ឃ **ហួត តាត** ផងដែរ។ លោក **ពិត យ៉ាថៃ** និងក្រុមគ្រួសាររបស់គាត់ បានវិលត្រលប់មកកាន់ផ្សារស៊ីឡូបិវិញ ដើម្បីមកយករបស់របរ។ ខណៈដែលពុំមាននរណាម្នាក់មកបន្ទាន់ពួកគាត់ ពួកគាត់បានបង្ខំចិត្តរៀបចំអីវ៉ាន់យ៉ាងប្រញាប់ប្រញាល់ ដោយសារតែអ្នកនៅជិតខាងដទៃទៀតបានចាកចេញរួចអស់ទៅហើយ។

លោក **ពិន យ៉ាថៃ** បានផ្តល់សក្ខីកម្មថា ប្រជាជនត្រូវតែធ្វើការជម្លៀសចេញពីទីក្រុងដោយយោងទៅលើទីកន្លែងដែលពួកគេបានចាប់ផ្តើមចេញដំណើរ អ្នកដែលចេញពីទិសខាងជើងនៅជាយក្រុង ត្រូវធ្វើដំណើរឆ្ពោះទៅកាន់ទិសខាងជើង ហើយអ្នកដែលនៅទិសខាងត្បូងត្រូវតែធ្វើដំណើរចេញទៅកាន់ទិសខាងត្បូង។ ដើមបណ្តឹងរដ្ឋប្បវេណី និងគ្រួសាររបស់គាត់ ដែលបានចាប់ផ្តើមចេញពីទិសខាងជើង បានចាកចេញពីទីក្រុងភ្នំពេញតាមបណ្តោយមហាវិថីព្រះមុនីវង្ស។ គាត់បានផ្តល់សក្ខីកម្មថា តាមដងមហាវិថីនេះ ពោរពេញទៅ

ដោយប្រជាជន ហើយមានអ្នកខ្លះជាអ្នកជម្ងឺដែលត្រូវបានបង្ខំឲ្យធ្វើដំណើរនៅលើគ្រែពេទ្យរបស់ពួកគេ។ លោក **ពិន យ៉ាថៃ** បាននិយាយថា គ្រប់ៗគ្នាបានយកចិត្តទុកដាក់លើអាយុជីវិតរបស់ពួកគេ និងគ្រួសារពួកគេផ្ទាល់ច្រើនជាងជួយអ្នកដទៃទៀត។

នៅតាមដងផ្លូវជាច្រើន មានមនុស្សម្នានៅកកកុញនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និងសាច់ញាតិរបស់គាត់ បានចំណាយពេលបួនម៉ោងដើម្បីទៅដល់មហាវិទ្យាល័យច្បាប់ ដែលជាទីកន្លែងដែលពួកគាត់បានស្នាក់នៅរយៈពេលបីថ្ងៃ។ នៅថ្ងៃទីបួន ខ្មែរក្រហម បានប្រាប់ពួកគាត់ឲ្យបន្តដំណើរឆ្ពោះទៅកាន់ទិសខាងជើង។ ដោយសារតែស្ពានព្រះមុនីវង្សត្រូវបានបិទ លោក **ពិន យ៉ាថៃ** បានដើរតាមផ្លូវឆ្ពោះទៅកាន់ តាខ្មៅ។ នៅតាមផ្លូវ ពួកគាត់បានឆ្លងកាត់ភូមិជាច្រើនដែលសុទ្ធតែគ្មានអ្វីទាំងអស់ រហូតដល់ពួកគាត់បានមកដល់ភូមិដំបូងគេ ក្នុងតំបន់រំដោះនៅព្រៃតូច។ គាត់បានសន្និដ្ឋានថា វាគឺជាតំបន់រំដោះ ពីព្រោះអ្នកនៅទីនោះត្រូវបានស្គាល់ថាជា "ប្រជាជនមូលដ្ឋាន" ហើយពួកគេសុទ្ធតែស្លៀកពាក់ខោអាវពណ៌ខ្មៅស្ទើរតែទាំងអស់គ្នា។

លោក **ពិន យ៉ាថៃ** បានគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា "តាមដែលស្ថានភាពម្នាក់ៗហ្នឹង អង្គការអត់មានមករវីរវល់នឹងយើងទេ" [6]។ នៅក្នុងសៀវភៅរបស់គាត់ លោក **ពិន យ៉ាថៃ** បានសរសេររៀបរាប់ពីសភាពអស់កម្លាំងដែលនិយាយពីអ្នកឈឺ និងអ្នករបួសនៅពេលនោះ។ គាត់បានរ៉ាយរ៉ាប់ពីរឿងនេះនៅក្នុងសវនាការដោយបានផ្ដល់សក្ខីកម្ម ពីចំនួនទាហានដែលគាត់ និងគ្រួសាររបស់គាត់បានឃើញនៅតាមផ្លូវ នៅខណៈដែលពួកគាត់បានធ្វើដំណើរចេញឆ្ងាយពីទីក្រុងភ្នំពេញ។ អ្នកដែលមិនអាចបន្តដំណើរទៅមុខបាន បានឈប់សម្រាកនៅតាមចិញ្ចើមផ្លូវ ហើយលោក **ពិន យ៉ាថៃ** បានផ្ដល់សាក្សីកម្មថា គាត់បានឃើញស្ត្រីពីរនាក់បានចងករបស់ពួកគេ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានរៀបរាប់ពីក្រុមគ្រួសារ និងសាច់ញាតិរបស់គាត់ថាមានសំណាងពីព្រោះពួកគាត់អាចនៅជាមួយគ្នា ហើយបានបន្តដំណើរដោយរថយន្ត។ ក្រុមគ្រួសាររបស់លោក **ពិន យ៉ាថៃ** ក៏អាចទិញអីវ៉ាន់ដោយប្រើប្រាស់ប្រាក់កាកបានផងដែរ ហើយនៅពេលនោះ រូបិយវត្ថុ (រៀល) នៅតែមានការទទួលយក នៅថ្ងៃខ្លះ បន្ទាប់ពីការជម្លៀសប្រជាជនចេញ។

## គ. ឈើខ្មៅ ខេត្តកណ្ដាល

យោងតាមដើមបណ្ដឹងរដ្ឋប្បវេណី នៅទីបញ្ចប់ គាត់ និងក្រុមគ្រួសាររបស់គាត់ បានមកដល់កោះធំ ដែលជាតំបន់ត្រួតពិនិត្យរបស់ខ្មែរក្រហម និងរឹបអូសយកឯកសារអត្តសញ្ញាណប័ណ្ណ។ នៅត្រង់ចំណុចនេះ គាត់បានបែកចេញពីបងប្អូនជីដូនមួយប្រុសរបស់គាត់ ដែលចង់ធ្វើដំណើរទៅខេត្ត តាកែវ ជាមួយនឹងគ្រួសាររបស់គាត់។ បន្ទាប់ពីចាកចេញកន្លែងត្រួតពិនិត្យរួចមក ក្រុមរបស់លោក **ពិន យ៉ាថៃ** ដែលដំបូងឡើយមានចំនួន ៣០នាក់ បានមករួមគ្នាតែ១៨នាក់ប៉ុណ្ណោះ ដោយបូករួមទាំងសមាជិកគ្រួសាររបស់គាត់ដោយផ្ទាល់ និងសាច់ញាតិមួយចំនួនខាងប្រពន្ធរបស់គាត់ផងដែរ។

ចម្ងាយមួយគីឡូម៉ែត្របន្ទាប់ពីកន្លែងត្រួតពិនិត្យ ខ្មែរក្រហម បានបញ្ឈប់ក្រុមរបស់ពួកគាត់ម្ដងទៀត ដើម្បីសាកសួរពួកគាត់ ហើយបានរឹបអូសយករូបិយប័ណ្ណបរទេសទាំងអស់ ទុកសម្រាប់ "អង្គការ"។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានផ្ដល់សក្ខីកម្មថា គាត់បានលះបង់លុយចោលចំនួន ៣០០០ដុល្លា ដែលគាត់

មាននៅនឹងគាត់ នៅពេលនោះ។ ពួកគាត់ត្រូវបានគេប្រាប់ឲ្យទុកឡាន និងកង់នៅកន្លែងនោះ ហើយខ្មែរក្រហមបានឲ្យក្រដាសមួយទុក ដូច្នេះពួកគាត់សង្ឃឹមថា ពេលក្រោយ ពួកគាត់អាចមកយកឡាននោះបានវិញ។ បន្ទាប់មក ពួកគាត់បានជិះទូកទៅកាន់ឈើខ្មៅក្នុងខេត្តកណ្តាល។ ក្រុមរបស់ពួកគាត់បានទៅដល់នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥។ ពួកគាត់បានដឹងថា នៅកន្លែងនេះ អ្នកភូមិត្រូវបានចាត់ទុកថាជា “ប្រជាជនមូលដ្ឋាន”។ នៅពេលដែលមាន “ប្រជាជនថ្មី” មកដល់តំបន់នេះ ប្រជាជនមូលដ្ឋានបានមកស្វាគមន៍ប្រជាជនថ្មី។ បន្ទាប់ពីអត្តសញ្ញាណរបស់ពួកគាត់ត្រូវបានត្រួតពិនិត្យចប់ ប្រជាជនដែលមកដល់ថ្មី ត្រូវបានផ្តល់អាហារយ៉ាងសមរម្យ។ បន្ទាប់ពីបានចំណាយពេលមួយយប់នៅវត្តឈើខ្មៅមក ប្រជាជនដែលមកដល់ថ្មីត្រូវបានបែងចែកផ្ទះឲ្យ។ ភាគច្រើន ប្រជាជនថ្មីបានរស់នៅជាមួយនឹងប្រជាជនមូលដ្ឋានក្នុងផ្ទះរបស់ពួកគេ។ ក៏ប៉ុន្តែ ដោយសារតែគ្រួសារ និងសាច់ញាតិរបស់លោក **ពិន យ៉ាថៃ** មានគ្នាច្រើន ពួកគាត់ត្រូវបានស្នើឲ្យទៅរស់នៅក្នុងកុដិព្រះសង្ឃនៅវត្តឯណោះ។

នៅថ្ងៃបន្ទាប់ មានការប្រកាសណែនាំឲ្យប្រជាជនចាប់ផ្តើមធ្វើការងារ។ ប្រជាជន ត្រូវធ្វើការតាមក្រុមដាច់ដោយឡែកពីគ្នាៈ កងបុរស និងកងស្ត្រី ចំណែកឯកងកុមារ ត្រូវធ្វើការជាមួយនឹងកងស្ត្រី។ ប្រជាជនថ្មីបានធ្វើការដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន។ ខ្មែរក្រហម ក៏បានប្រមូលយកព័ត៌មានផងដែរពីអាកប្បកិរិយារបស់ប្រជាជនតាមរយៈពួកឈ្លប។ លោក **ពិន យ៉ាថៃ** បានអះអាងថា មានមនុស្ស “ស្លាប់ច្រើនបង្គួរ” នៅទីកន្លែងនោះ។ ថ្វីបើប្តីប្រពន្ធត្រូវបានអនុញ្ញាតឲ្យសម្រាកដើម្បីធ្វើពិធីកាន់ទុកក៏ដោយ លោក **ពិន យ៉ាថៃ** បានផ្តល់សក្ខីកម្មថា មិនមានព្រះសង្ឃដើម្បីជួយរៀបចំពិធីបុណ្យបញ្ចុះសពឡើយ។ ទាក់ទងនឹងរចនាសម្ព័ន្ធនយោបាយនៅឈើខ្មៅ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានអះអាងថា មានប្រធានម្នាក់ អនុប្រធានម្នាក់ និងលេខាម្នាក់ ដែលជាអ្នកមើលការខុសត្រូវជំនួយការជាច្រើននាក់ ដែលមានតួនាទីក្នុងការអប់រំ វិន័យ និងសុខភាព។

បន្ទាប់ពីបានរស់នៅឈើខ្មៅអស់រយៈពេលបីខែមក មានការប្រកាសថា ប្រជាជនអាចអនុញ្ញាតឲ្យវិលត្រលប់ទៅកាន់ភូមិកំណើតរបស់ពួកគេវិញ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានស្ម័គ្រចិត្តវិលត្រលប់មកភូមិកំណើតគ្រួសាររបស់គាត់វិញនៅឧដុង្គក្នុងខេត្តកំពង់ស្ពឺ។ ពួកគាត់ បានធ្វើដំណើរដោយដើរ និងយានយន្ត ក៏ប៉ុន្តែបន្ទាប់ពីធ្វើដំណើរបាន ១៥គីឡូម៉ែត្រមក ពួកគាត់ត្រូវបានបង្វែងឲ្យទៅកាន់ស្រុកសមរលាភ ក្នុងខេត្តតាកែវវិញ។ តាមឲ្យដឹងមក កម្មាភិបាលខ្មែរក្រហម បានប្រាប់ពួកគាត់ថា ដោយសារតែវាជាខែស្ទូងស្រូវ កិច្ចការរបស់ពួកគាត់ តម្រូវឲ្យធ្វើស្រែនៅទីតាំងនោះតែម្តង។ ពួកកម្មាភិបាលទាំងនោះ បានសន្យាថា ពួកគាត់ នឹងត្រូវអនុញ្ញាតឲ្យបន្តដំណើរទៅកាន់ភូមិកំណើតរបស់ពួកគាត់ នៅបន្ទាប់ពីពួកគាត់បានស្ទូងស្រូវរួចរាល់។

## ឃ. សមរលាភ ខេត្តតាកែវ

លោក **ពិន យ៉ាថៃ** និងក្រុមគ្រួសាររបស់គាត់ បានស្នាក់នៅអស់រយៈពេលបួនខែនៅសមរលាភ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៥។ នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី នៅតែមានសមាជិកគ្រួសារ ១៨នាក់ នៅជាមួយនឹងគាត់។ នៅកន្លែងថ្មីនេះ ប្រជាជនថ្មី មិនត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយប្រជាជនមូលដ្ឋានទេ។ គាត់បានសង្កេតឃើញថា ប្រជាជនត្រូវបានចាត់ចែងទីកន្លែងសម្រាប់រស់នៅ ដោយយោងតាមអតីតភាព

ការងាររបស់ពួកគេនៅក្នុងរបបមុន។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានចាត់ឲ្យចូលក្នុងក្រុមអ្នករដ្ឋការ ។ ដោយសារតែនៅសមរលាវ មិនមានទឹកគ្រាប់គ្រាន់ ប្រជាជនត្រូវបានបញ្ជាឲ្យសាងទំនប់ទឹក បន្ថែមលើការងារធ្វើស្រែ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានធ្វើការសង្កេតផងដែរថា នៅទីតាំងនេះ កុមារត្រូវបានចាត់ឲ្យធ្វើការងារនៅក្នុងកងផ្ទាល់របស់ពួកគេ ជំនួសឲ្យកងស្ត្រី។

នៅខែកញ្ញា ឆ្នាំ១៩៧៥ មេភូមិបានស្នើឲ្យមានអ្នកស្ម័គ្រចិត្តដើម្បីទៅកាន់ខេត្តបាត់ដំបង។ ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់គាត់ បានស្ម័គ្រចិត្ត ដោយសារតែពួកគាត់សង្ឃឹមទុកថា នឹងអាចរស់នៅបានប្រសើរជាងនេះ ហើយក៏មានបំណងថាពួកគាត់ប្រហែលជាអាចរត់ទៅកាន់ប្រទេសថៃ តាមរយៈខេត្តដែលនៅជាប់នឹងព្រំដែននេះ។ ក្រុមដែលមានសមាជិក១៨នាក់ បានធ្វើដំណើរកាត់ផ្លូវជាតិលេខ៣ ហើយបានស្នាក់នៅក្នុងវត្តអង្គរការអស់ពីរសប្តាហ៍។ ប្រជាជនថ្មីដែលមកពីភូមិដទៃទៀតនៅតំបន់ភាគនិរតី ក៏បានបញ្ជូនមកទីនោះផងដែរ ដើម្បីរង់ចាំការឡានដឹកជញ្ជូនបន្ត។ លោក **ពិន យ៉ាថៃ** បានកត់សម្គាល់ប្រជាជនថ្មីដោយសារតែពួកគេមានសម្លៀកបំពាក់ពណ៌ចម្រុះ។ បន្ទាប់ពីពីរសប្តាហ៍មក មានឡានដឹកជញ្ជូនគ្មានដំបូលចំនួនពី ២០ ទៅ៣០គ្រឿង បានមកដល់ ហើយដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់គាត់ បានជិះឡានទាំងនោះ ជាមួយមនុស្សប្រហែល ២០០០នាក់ទៀត។ ក្នុងឡាននីមួយៗ ផ្ទុកប្រជាជនប្រមាណពី៨០ទៅ១០០នាក់ ហើយឡានទាំងនោះ បានធ្វើដំណើរដោយមិនខ្វល់ពីអាកាសធាតុ ឬតម្រូវការអ្នកដំណើរឡើយ។ លោក **ពិន យ៉ាថៃ** បានផ្តល់សក្ខីកម្មថា មានប្រជាជនពីរនាក់នៅក្នុងឡានរបស់គាត់បានសន្លប់ ហើយក្រោយមកបានស្លាប់។

ឡានដឹកអ្នកដំណើរ បានធ្វើដំណើរតាមផ្លូវជាតិលេខ៣ ហើយបន្ទាប់មកតាមផ្លូវជាតិលេខ៤ ដោយបានឆ្លងកាត់អាកាសយានដ្ឋានពោធិ៍ចិនតុង។ ផ្សារពោធិ៍ចិនតុង មានសភាពស្ងាត់ជ្រងំ ហើយផ្ទះនៅជុំវិញត្រូវបានគេបោះបង់ចោល។ ផ្លូវពុំមានចរាចរធ្វើដំណើរទៅវិញទៅមកទេ ហើយស្ពានជ្រោយចង្វាត្រូវបានបំផ្លាញខ្ទេចអស់។ ក៏ប៉ុន្តែ លោក **ពិន យ៉ាថៃ** បានផ្តល់សក្ខីកម្មថា គាត់បានឃើញមានរោងចក្រមួយចំនួននៅដំណើរការនៅព្រែកព្នៅ ដោយមានប្រជាជនមូលដ្ឋាន និងកម្មាភិបាលខ្មែរក្រហមកំពុងធ្វើការនៅទីកន្លែងនោះ។ ឡានដឹកអ្នកដំណើរ បានឈប់សម្រាកមួយសន្ទុះនៅកំពង់ឆ្នាំង។ ហើយការធ្វើដំណើរ បានបន្តនៅថ្ងៃបន្ទាប់ ដែលបានបន្តធ្វើដំណើររហូតដល់ពួកគាត់ បានមកដល់ស្ពានមួយក្នុងខេត្តពោធិ៍សាត់។ តាមឲ្យដឹងមក យោធាខ្មែរក្រហមដែលកំពុងធ្វើដំណើរជាមួយនឹងប្រជាជនទាំងនេះ បានជួបប្រជុំគ្នានៅត្រង់ទីតាំងនេះ។ ក្បួនរថយន្តដឹកអ្នកដំណើរ បានឈប់តាមផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ខេត្តបាត់ដំបង ហើយបានបញ្ចប់ដំណើរនៅលាជ។ បន្ទាប់មក អ្នកដំណើរទាំងអស់ ត្រូវបានប្រាប់ឲ្យចុះពីរថយន្ត។ នៅថ្ងៃបន្តបន្ទាប់ មានឡានដឹកអ្នកដំណើរជាច្រើនបានមកដល់ទីកន្លែងនោះ ហើយពួកគេបានមកផ្តុំគ្នាដើម្បីបង្កើតជាជំរំនៅម្តុំក្បែរទន្លេមួយ។ ចាប់ពីកន្លែងនោះមក ប្រជាជនត្រូវបានបែងចែកជាក្រុមៗ ហើយត្រូវបានបញ្ជូនទៅកាន់ទីតាំងផ្សេងៗគ្នា។ ក្រុមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅមានសមាជិកគ្រួសាររបស់គាត់ ត្រូវបានបញ្ជូនទៅនៅក្នុងព្រៃមួយនៅវាលវង់ ឆ្ពោះទៅកាន់ប៉ែកខាងជើងនៃភ្នំក្រវាញ់។

## ង.	ជីវិតនៅវាលវង់ និងភូមិដូនអីមួយ

ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានផ្ដល់សក្ខីកម្មថា គាត់ និងក្រុមគ្រួសាររបស់គាត់ បានរស់នៅវាលវង់ ក្នុងតំបន់ទិសពាយព្យចាប់តាំងពីខែកញ្ញា រហូតដល់ខែធ្នូ ក្នុងឆ្នាំ១៩៧៥។ បន្ទាប់មកទៀត ខ្មែរក្រហមបានស្នើឲ្យមានអ្នកស្ម័គ្រចិត្តផ្លាស់ទៅកាន់ទីតាំងដទៃទៀត ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និងគ្រួសាររបស់គាត់ ក៏បានយល់ព្រមតាមការស្នើសុំនោះ។ ពួកគាត់ បានផ្លាស់ទៅទីតាំងដទៃទៀតនៅក្នុងតំបន់តែមួយ ដែលគេហៅ "ភូមិប្រាំពីរ"។

លោក **ពិន យ៉ាថៃ** បានរៀបរាប់ពីតំបន់វាលវង់ថា ជា "កន្លែងវេទនាបំផុត"។ គាត់ បានប៉ាន់ស្មានថាមានប្រជាជនប្រមាណ ៥០០០នាក់ នៅក្នុងព្រៃនៅពេលនោះ ក៏ប៉ុន្តែមួយភាគបីបានស្លាប់ក្នុងអំឡុងពេលបួនខែដែលគាត់បានស្នាក់នៅទីកន្លែងនោះ។ ក្រុមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានគ្នា១៨នាក់ ត្រូវបានបែងចែកជាពីរក្រុម។ លោក **ពិន យ៉ាថៃ** បានរស់នៅជាមួយនឹងកូន ប្រពន្ធ និងបងប្អូនប្រុសជីដូនដ៏តូចម្នាក់របស់គាត់។ គ្រួសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានចែកដីឲ្យដាំដំណាំចំនួន ២៥គីឡូម៉ែត្រការេ ខណៈដែលឪពុកម្ដាយរបស់គាត់ ត្រូវបានបែកចែកឲ្យដាំដំណាំនៅដីម៉ុផ្សេងទៀត។

ពីរបីសប្ដាហ៍បន្ទាប់ពីការមកវាលវង់ ដើមបណ្ដឹងរដ្ឋប្បវេណី បានឃើញអ្នកមកដល់ថ្មីជាច្រើនត្រូវបាននាំទៅក្នុងព្រៃនេះកាន់តែជ្រៅទៅៗ។ អ្នកមកដល់ថ្មីថ្មោង ត្រូវបានប្រាប់ឲ្យឆ្ការព្រៃ នៅលើដីដែលបានលែទុកឲ្យដើម្បីធ្វើស្រែ ហើយនិងសង់ទីជម្រកដោយខ្លួនពួកគេ ដោយមិនបានផ្ដល់នូវឧបករណ៍អ្វីឡើយ។ ពួកគេ ត្រូវបានអនុញ្ញាតឲ្យឈប់ធ្វើការនៅចម្ការរបស់ពួកគេរៀងរាល់១០ថ្ងៃម្ដង ដើម្បីស្វែងរកអាហារសម្រាប់ចិញ្ចឹមជីវិត។ ការងារនៅទីនោះ គឺមានសភាពឃោឃៅជាងការងារនៅតំបន់ពីមុនៗ ហើយតាមដែលបានដឹងមកទាហានខ្មែរក្រហម គឺជាអ្នកគ្រប់គ្រងពួកគេ។ ពួកគេ បានក្រោកពីដេកនៅម៉ោង ៦ព្រឹក សម្រាកបរិភោគអាហារចន្លោះម៉ោង១ថ្ងៃត្រង់ ហើយបន្តធ្វើការរហូតដល់ម៉ោង៦ល្ងាច។ ចាប់តាំងពីសប្ដាហ៍ដំបូងនៃការមកដល់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រជាជន បានបន្តស្លាប់ ហើយត្រូវបានបញ្ចុះនៅក្នុងព្រៃ។ ក្រៅពីការស្រេកឃ្លាន និងធ្វើការជាទម្ងន់ ប្រជាជនមួយចំនួនបានស្លាប់ដោយសារតែពុលអាហារ និងខ្វះខាតថ្នាំសង្កូវព្យាបាល។ ដោយសារតែមានចំនួនអ្នកស្លាប់បានកើនឡើង ពេលខ្លះជិតដល់១០នាក់ក្នុងមួយថ្ងៃ មេភូមិបានចាត់ឲ្យមានអ្នកកប់សាកសព ដោយសារតែគ្រួសាររបស់អ្នកស្លាប់ មានកម្លាំងខ្សត់ខ្សោយពេកក្នុងការបញ្ចុះអ្នកស្លាប់។

ទាក់ទងនឹងការផ្ដល់សក្ខីកម្មអំពីការបែងចែករបបអាហារ ដើមបណ្ដឹងរដ្ឋប្បវេណី បានប្រាប់ឲ្យដឹងថាដំបូងឡើយ ប្រជាជនបានទទួលអង្ករមួយកំប៉ុងសម្រាប់មនុស្សពីរនាក់។ នៅពេលក្រោយមក របបអាហារបានថយចុះមកត្រឹមមួយកំប៉ុងសម្រាប់មនុស្សប្រាំមួយនាក់ ហើយបន្ទាប់មកថយសល់មួយកំប៉ុងសម្រាប់មនុស្សប្រាំបីនាក់។ ប្រជាជនបានស្លាប់ ជាពិសេសអ្នកដែលមិនមានរបស់របរ ដែលអាចដោះដូរយកអាហារបន្ថែមបាន។ ដោយសារតែលោក **ពិន យ៉ាថៃ** ធ្លាប់មានប្រវត្តិមកពីគ្រួសារស្ដុកស្ដម្ភ ហើយគាត់ និងសមាជិកគ្រួសាររបស់គាត់អាចដោះដូររបស់របររបស់ពួកគាត់មួយចំនួន ដើម្បីយកអង្ករបន្ថែមពីពួកខ្មែរក្រហម។ ដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាពីទិដ្ឋភាពនេះថា៖ "គឺថាអ្នកក្រដែលគេចង់ការពារហ្នឹង ស្លាប់មុនអ្នកមាន ដោយសារតែពួកគេមិនមានអ្វីដើម្បីដោះដូរយកអាហារ។"[7]

ទោះបីជាមានលក្ខខណ្ឌគ្រាន់បើដូចខាងលើក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណី បានបាត់បង់សមាជិកគ្រួសាររបស់គាត់ផងដែរ មានដូចជា កូនពៅពីរនាក់ ម្តាយក្មេក និងប្អូនប្រុសរបស់គាត់។ **សុជាត** ដែលជាកូនប្រុសអាយុ១០ឆ្នាំរបស់លោក **ពិន យ៉ាថៃ** ត្រូវបានបង្ខំឲ្យធ្វើការលើសកម្លាំង។ នៅពេលដែល **សុជាត** បានមានរបួសជើងរបស់គាត់ ឪពុកម្តាយរបស់គាត់បានសម្រេចចិត្តឲ្យទុកគាត់សម្រាកនៅផ្ទះ។ ខ្មែរក្រហម បានមកដល់ផ្ទះរបស់ពួកគាត់ ហើយបានស្តីបន្ទោសពួកគាត់ថា មិនដឹងអី ដោយថា កូនប្រុសរបស់លោក **ពិន យ៉ាថៃ** ជាកម្មសិទ្ធិរបស់អង្គការ ហើយមិនមែនជារបស់គ្រួសាររបស់គាត់នោះទេ។ **សុជាត** ត្រូវបាននាំត្រឡប់មកធ្វើការវិញ។ នៅថ្ងៃបន្ទាប់មក លោក **ពិន យ៉ាថៃ** ត្រូវបានគេប្រាប់ថា កូនប្រុសរបស់គាត់បានដួល ហើយស្លាប់នៅពេលដែលកំពុងធ្វើការ។

នៅខែមករា ឆ្នាំ១៩៧៦ ដើមបណ្តឹងរដ្ឋប្បវេណី បានមកស្នាក់នៅក្នុងភូមិដូនអ៊ីមួយ។ ការបរិភោគអាហាររួម ត្រូវបានរៀបចំឡើងនៅក្នុងភូមិដូនអ៊ីមួយ បន្ទាប់ពីមានការប្រកាសនូវរដ្ឋធម្មនុញ្ញថ្មីរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជន ត្រូវបានដកហូតផងដែរនូវរបស់របររបស់ពួកគេ ដើម្បីធានាថា ពួកគេមិនអាចចម្អិនអាហារដោយខ្លួនឯងបានទៀត។ យោងតាមលោក **ពិន យ៉ាថៃ** អាហារ មានគ្រប់គ្រាន់សម្រាប់រយៈពេលពីរ បីសប្តាហ៍ដំបូងនៃប្រព័ន្ធហូបចុកថ្មីនេះ ក៏ប៉ុន្តែក្រោយមក វានៅតែមិនមានគ្រប់គ្រាន់ដដែរ។

## ច. កិច្ចប្រជុំសិក្សារៀនសូត្រ

នៅថ្ងៃទីពីរដែលដើមបណ្តឹងរដ្ឋប្បវេណីទៅដល់ឈើខ្មៅ ខ្មែរក្រហម បានប្រមូលផ្តុំអ្នកដំណើរមកពីភ្នំពេញទាំងអស់ឲ្យមកចូលរួមកិច្ចប្រជុំ។ ខ្មែរក្រហមបានពន្យល់ថា អង្គការអត់ថាអីដល់ប្រជាជនដែលជម្លៀសមកពីភ្នំពេញ ដែលធ្លាប់ជាអ្នកធ្វើការឲ្យរបបចាស់នោះទេ ហើយពួកគេត្រូវតែខំរៀនសូត្រ។ ពួកគេត្រូវបានស្នើឲ្យចូលរួម "ធ្វើការបដិវត្តន៍" ដូច្នេះពួកគេអាចនឹងទទួលបាន "ការយកចិត្តទុកដាក់ថែទាំពីអង្គការ"។

លោក **ពិន យ៉ាថៃ** ក៏បានរៀបរាប់ពីកិច្ចប្រជុំនយោបាយលើកដំបូងដែលគាត់បានចូលរួម។ ប្រជាជនថ្មី ត្រូវបានគេសន្យាថា នឹងត្រូវបានអត់ឱនឲ្យ អត់មានយកទោសពៃអីទេ សូមឲ្យតែពួកគេ "ធ្វើការកែខ្លួនធ្វើការបដិវត្តន៍"។[៨] សម្រាប់បុរស គឺរួមមាន ការធ្វើការ ហើយនិងការទុកសក់ឲ្យខ្លី។

ដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយថា ពួកគាត់ត្រូវតែចូលរួម "ប្រជុំជីវភាព" ក្នុងចន្លោះពេលបីទៅបួនថ្ងៃម្តង ។ ការប្រជុំទាំងនេះ គឺដូចគ្នានឹងការប្រជុំស្វ័យតិទៀន។ ប្រជាជនថ្មី ជាញឹកញាប់ បានទទួលការអប់រំលើបញ្ហាដែលទាក់ទងនឹងសង្គមថ្មី ហើយនិងការងារដែលពួកគេត្រូវធ្វើ។

## ឆ. ទណ្ឌកម្មលើការប្រព្រឹត្តិល្មើសនៅថ្នាក់សហករណ៍

មានពេលមួយនោះ សាច់ញាតិមួយចំនួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានមករកគាត់ដើម្បីសុំចែកអង្ករបន្ថែម។ លោក **ពិន យ៉ាថៃ** បានផ្តល់សក្ខីកម្មថា ខ្មែរក្រហមបានដឹងពីរឿងនេះ ហើយបានចាប់ខ្លួនពួកគេ។ បងប្រុសសាច់ថ្លៃរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនមិនគ្រប់ទឹក ក៏ត្រូវបានចាប់ខ្លួនផងដែរ ហើយបន្ទាប់មក បានបាត់ខ្លួនបន្ទាប់ពីគាត់បាននិយាយទិតៀនរបបខ្មែរក្រហម។

ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានរៀបរាប់ផងដែរថា មានប្រជាជន២០០នាក់ បានធ្វើបាតុកម្មនៅវាលវង់ ដោយសារតែរបបអង្គរមិនបានចែកឲ្យពួកគេអស់ពីរថ្ងៃមកហើយ។ មេភូមិ បានសុំឲ្យប្រជាជននៅស្ងប់ស្ងាត់ ហើយបានសុំឲ្យពួកគេ "មានចិត្តធ្វើបដិវត្តន៍" ដោយមិនបំផ្លិចបំផ្លាញសណ្តាប់ធ្នាប់សាធារណៈ។ បាតុករទាំងនោះ ត្រូវបានធានាថា របបអង្គរនឹងបើកជូនពួកគាត់នៅពីរបីថ្ងៃក្រោយ។ របបអង្គរ ពិតជាបានមកយ៉ាងទៀងទាត់មែន ក៏ប៉ុន្តែមេដឹកនាំបាតុកម្ម ត្រូវបានចាប់ខ្លួន និងបានបាត់ខ្លួនបន្ទាប់ពីនោះមក។

## ជ. គោលនយោបាយខ្មែរក្រហម និងការអនុវត្តន៍អំពើពុករលួយ

តាមគោលបំណងទូទៅនៃការជម្លៀសប្រជាជនចេញពីទីក្រុង លោក **ពិន យ៉ាថៃ** និងសមាជិកក្រុមគ្រួសាររបស់គាត់ បានយល់ឃើញថា អង្គការមិនចង់ឲ្យមានកម្មសិទ្ធិឯកជន ការប្រើប្រាស់លុយកាក់ ការធ្វើពាណិជ្ជកម្ម ឬក៏មានប្រព័ន្ធយុត្តិធម៌ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឡើយ។ លោក **ពិន យ៉ាថៃ** បានផ្តល់សក្ខីកម្មថា គាត់បានសង្កេតឃើញថា វាគឺជាផ្នែកមួយនៃការបំផ្លាញដោយសាររបបមុន ហើយខ្មែរក្រហមបានចាត់ទុកថា ការបំផ្លាញនេះកើតឡើងដោយពួកសក្តិភូមិនិយម និងពួកចក្រពត្តិនិយម។ គាត់បានអះអាងថា ការជម្លៀសប្រជាជនចេញពីទីក្រុង ក៏ជាផ្នែកមួយនៃការខំប្រឹងប្រែងរបស់ខ្មែរក្រហមដើម្បីលើកតម្កើងអ្នកទន់ខ្សោយ ហើយបង្កើតជាសង្គមមួយដែលពុំមានអំណាចជិះជាន់។ ក៏ប៉ុន្តែ គាត់បានសង្កេតថា ក្នុងការអនុវត្តជាក់ស្តែង "អ្នកទន់ខ្សោយបានងាប់ ដោយសារតែពួកគេត្រូវបានបញ្ជូនទៅទីកន្លែងដែលពិបាករស់នៅខ្លាំងពេក"។[9] ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មបន្ថែមពីអ្វីដែលបាននឹកឃើញ ទាក់ទិននឹងពាក្យសម្តីរបស់ **មិត្តប៉ិច** ដែលជាមន្ត្រីខ្មែរក្រហមជាន់ខ្ពស់ថ្នាក់ខេត្ត។ យោងតាមដើមបណ្តឹងរដ្ឋប្បវេណី **ប៉ិច** បានអះអាងថា វៀតណាម មិនមែនជា "អ្នកបដិវត្តន៍សុទ្ធសាធទេ" ពីព្រោះគេមិនបានបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងឡើយ។ **មិត្តប៉ិច** បានបញ្ជាក់ថា ប្រការនេះ បានធ្វើឲ្យវៀតណាមងាយនឹងឆាប់ទាស់គ្នា ខណៈដែលយើងមានការពិបាកក្នុងការ "តាមដានអំពីពួកអ្នកដែលប្រឆាំងនឹងបដិវត្តន៍ណាស់" ក្នុងទីក្រុងនេះ។[10] ការជម្លៀសប្រជាជនចេញពីទីក្រុងនេះ គឺជាវិធានការមួយក្នុងការលុបបំបាត់ "មេរោគវីរុសដែលប្រឆាំងនឹងសង្គមខ្មែរក្រហម"។[11]

មេធាវីការពារក្តី លោក **កាណាវ៉ាស** បានសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសម្រង់ខ្លីៗដែលបានលើកឡើងក្នុងសៀវភៅរបស់គាត់ ដែលថា ការដួលរលំនៃទីក្រុងភ្នំពេញ គឺបណ្តាលមកពីគោលនយោបាយអាមេរិកាំងដើម្បីផ្គត់ផ្គង់ដល់ក្រុមដែលគាំទ្រចិនក្នុងរណសិរ្សរួបរួមជាតិកម្ពុជា។ ដើមបណ្តឹងរដ្ឋប្បវេណីបានទាញការសន្និដ្ឋាននេះ ចេញពីឧត្តមសេនីយ៍ **ហាប្បនា ងិន** ដែលគាត់បានជួបនៅពេលដែលពួកគាត់បានជ្រកកោននៅក្នុងមហាវិទ្យាល័យច្បាប់។ មេធាវីការពារក្តី ក៏បានដកស្រង់នូវផ្នែកមួយចំនួនចេញពីសៀវភៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលថា តាមការកត់សម្គាល់របស់គាត់ "ពួកខ្មែរក្រហមគ្មានក្បួនខ្នាតគ្មានច្បាប់ក្នុងប្រទេសឡើយ"[12] ការទាញសន្និដ្ឋាននេះ បានធ្វើឡើងនៅពេលលោក **ពិន យ៉ាថៃ** បានឆ្លងកាត់សហករណ៍ជាច្រើនដែលមានកម្រិតការងារ និងការរស់នៅប្លែកៗពីគ្នា។ លោក **ពិន យ៉ាថៃ** បានបញ្ជាក់ថា ភាពខុសប្លែកគ្នានេះ បានកើតមានក្នុងអំឡុងពេលបីខែដំបូងនៃការជម្លៀសប្រជាជនចេញពីទីក្រុង។ ដើមបណ្តឹងរដ្ឋប្បវេណី ក៏បញ្ជាក់ផងដែរថា នៅពេលដែលគាត់ និងគ្រួសាររបស់គាត់ បានស្ម័គ្រចិត្តជម្លៀសចេញក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលខុសៗគ្នានេះ គាត់បានជួបប្រជាជនមកពីភូមិដទៃទៀតនៅក្នុងវត្តអង្គរកា ដែលពួកគេមិនបានស្ម័គ្រចិត្តក្នុងការចាកចេញនោះទេ។

ចំពោះបញ្ហាអំពើពុករលួយ ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា កម្មាភិបាលខ្មែរក្រហម មានការជាប់ពាក់ព័ន្ធក្នុងការអនុវត្តទាក់ទងនឹងរបបអង្ករ និងការបែងចែកអង្ករ។ លោក **ពិន យ៉ាថៃ** បានបញ្ចេញមតិថា ចំនួនអ្នកស្លាប់ក្នុងចំណោមអ្នកដែលមកដល់ថ្មីថ្មោង មិនបានធ្វើឲ្យខ្មែរក្រហមមានការពិបាកឡើយ ពីព្រោះនេះមានន័យថា ធ្វើឲ្យពួកគេអាចនឹងទទួលបានរបបអាហារកាន់តែប្រសើរឡើង។ គាត់បានសង្ស័យថា តើថ្នាក់លើបានផ្តល់របបអង្ករដល់កម្មាភិបាលចំនួន ៤៥០០នាក់ឬ បើតាមជាក់ស្តែង មានតែ៤០០០នាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត។ ខ្មែរក្រហម បានទុកអង្ករដែលនៅសល់សម្រាប់ពួកគេ ហើយបានប្រើអង្ករទាំងនោះសម្រាប់ដោះដូរជាមួយនឹងគ្រួសារដែលជម្លៀសចេញពីទីក្រុង។

## ឈ. ការតាមរកបញ្ញវន្ត និងអតីតមន្ត្រីរដ្ឋការ លន់ នល់

យោងតាមសក្ខីកម្មរបស់គាត់ នៅខណៈពេលដែលស្នាក់ក្នុងសាលាច្បាប់ ដើមបណ្តឹងរដ្ឋប្បវេណី បានជួបនឹងឧត្តមសេនីយ៍ **ហាប្បនា ងិន** ដែលជាអតីតរដ្ឋមន្ត្រីសាធារណការ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសម័យ **លន់ នល់** ។ គាត់ ក៏បានជួបលោកស័ក្តិ៥ **ឡុង ម៉ន** ផងដែរ។ ក្នុងអំឡុងពេលនៃការស្នាក់នៅរបស់គាត់ គាត់បានឮថា អ្នកទាំងពីរនេះត្រូវបានចាប់ខ្លួនយកទៅបាត់ហើយ។

លោក **ពិន យ៉ាថៃ** ក៏បានរៀបរាប់ផងដែរថា ក្នុងអំឡុងពេលស្នាក់នៅក្នុងវត្តអង្គរកា គាត់បានឮពាក្យចចាមអារ៉ាមថា **សម្តេច សីហនុ** នឹងយាងមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ។ នៅវាលវង់ មេភូមិបានអះអាងពីពាក្យចចាមអារ៉ាមនេះ ហើយបាននិយាយថា នឹងមានរដ្ឋាភិបាលថ្មីមួយ ត្រូវបង្កើតឡើងដើម្បីកសាងប្រទេសជាតិឡើងវិញ។ ដោយសារតែហេតុផលនេះ អ្នកជំនាញផ្នែកវិស្វកម្ម ឬឱសថ (ដែលបានបញ្ចប់ការសិក្សារួមមក) ក៏ដូចជាមន្ត្រីយោធាផងដែរ ត្រូវបានស្នើឲ្យចុះឈ្មោះ ដើម្បីឲ្យពួកគេអាចចូលធ្វើការបម្រើឲ្យរដ្ឋាភិបាលថ្មីនេះ។ មានប្រជាជនចំនួន ៤០នាក់ បានឆ្លើយតបតាមការអំពាវនាវនេះ។ ពួកគេទាំងនោះ ត្រូវបានដឹកចេញទៅកាន់ទីក្រុងភ្នំពេញ ហើយបន្ទាប់មកបានបាត់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី បានឮពាក្យចចាមអារ៉ាមថា ពួកគេទាំងអស់នោះ ត្រូវបានអង្គការសម្លាប់ចោល។

## ញ. ការធ្វើដំណើររបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីរត់គៀសខ្លួនទៅកាន់ប្រទេសថៃ

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៧៧ ដើមបណ្តឹងរដ្ឋប្បវេណីបានរត់គៀសខ្លួនចេញពីប្រទេសកម្ពុជា ហើយបានចូលទៅកាន់ប្រទេសថៃ។ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម គាត់បានរៀបរាប់នូវអ្វីដែលបានកើតឡើងមកលើរូបគាត់បន្ទាប់ពីបានរត់គៀសខ្លួនមក។ ដំបូងឡើយ គាត់ត្រូវបានសាកសួរដោយសមត្ថកិច្ចថៃ ហើយបានឃាត់ខ្លួនអស់មួយសប្តាហ៍ ដោយសារតែគាត់មិនមានឯកសារសម្រាប់ធ្វើដំណើរ។ បន្ទាប់មក គាត់ត្រូវបានដឹកបញ្ជូនទៅកាន់ជំរំគៀសខ្លួនម៉ៃរុត ដែលនៅទីនោះមានអ្នកកាសែតជាច្រើនបានធ្វើបទសម្ភាសន៍ជាមួយគាត់។ ដើមបណ្តឹងរដ្ឋប្បវេណី បានសម្រេចចិត្តនិយាយរឿងរបស់គាត់ចេញមកក្រៅ ដោយសារតែមានសមាជិកគ្រួសារមួយចំនួនរបស់គាត់ ត្រូវបានខ្មែរក្រហមសម្លាប់ ហើយគាត់ចង់ទម្លាយព័ត៌មានអំពីអំពើឃោរឃៅនេះ។

បន្ទាប់ពីប្រទេសបារាំង បានទទួលការស្នើសុំសិទ្ធិសុំជ្រកកោនរបស់គាត់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ១៩៧៧ មក គាត់បានធ្វើដំណើរជុំវិញពិភពលោក មានដូចជាទៅកាន់ទីក្រុងបារីស វ៉ាស៊ីនតោន និងព្រុចសែល ហើយបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពីទុក្ខវេទនាយ៉ាងឈឺចាប់មកលើប្រជាជនកម្ពុជា។ លោក **ពិន យ៉ាថៃ** បានពិពណ៌នាក្នុងអំឡុងពេលនៃការរងទុក្ខវេទនានោះ ពីរបៀបដែលប្រទេសមហាអំណាច បានអះអាងគាំទ្រលើផ្នែកសិទ្ធិមនុស្ស ក៏ប៉ុន្តែបានបរាជ័យដើម្បីធ្វើសកម្មភាពដោះស្រាយស្ថានភាពនៅប្រទេសកម្ពុជា។

## ង. ការថ្លែងពីទុក្ខវេទនា ឥរិយាបថ និងភាពគួរជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី

លោក **ពិន យ៉ាថៃ** បានបញ្ជាក់ថា គាត់ជាអ្នករស់រានមានជីវិតតែម្នាក់គត់នៃគ្រួសាររបស់គាត់ដែលមានសមាជិក១៨នាក់។ គាត់បានបាត់បង់ទ្រព្យសម្បត្តិ ការងារ ប្រពន្ធ កូនៗ ឪពុកម្តាយ និងសាច់ញាតិរបស់គាត់។ ដើមបណ្តឹងរដ្ឋប្បវេណី មានអំណរគុណដែលតុលាការនេះ បានអនុញ្ញាតឲ្យគាត់មានឱកាសមកផ្តល់សក្ខីកម្មជាជនរងគ្រោះម្នាក់ ហើយគាត់បានបង្ហាញពីសេចក្តីរីករាយដែលតុលាការនេះត្រូវបានបង្កើតឡើង។ លោក **ពិន យ៉ាថៃ** បានស្នើសុំឲ្យមានការជំនុំជម្រះឲ្យបានឆាប់រហ័ស ដើម្បីផ្តល់នូវយុត្តិធម៌សម្រាប់ជនរងគ្រោះ ហើយស្នើសុំទៅកាន់ជនជាប់ចោទឲ្យសម្តែងការស្មោះត្រង់។ គាត់បានសុំជនជាប់ចោទឲ្យចូលរួមយ៉ាងស្ម័គ្រចិត្តនៅក្នុងសារភាព ទាក់ទិននឹងការដឹកនាំរបស់ពួកគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

> ដើម្បីសម្រេចគោលបំណងនេះ ខ្ញុំសូមធ្វើការអំពាវនាវដោយស្មោះ និងដោយទទូចដល់អស់លោកជាជនជាប់ចោទទាំងបីនាក់ ដែលធ្លាប់ជាអ្នកបដិវត្តន៍ដ៏ឆ្នើម មានមនសិការនយោបាយដ៏មោះមុត សូមលោកប្រកាន់ការទទួលខុសត្រូវខ្ពស់ក្នុងប្រវត្តិសាស្ត្រយើង ដោយស្ម័គ្រចិត្ត ធ្វើការសារភាពចំពោះការដឹកនាំអង្គការបដិវត្តន៍ ក្នុងរយៈពេលដែលអស់លោកនៅកាន់អំណាចទាំងស្រុង។ បើអស់លោកជាជនជាប់ចោទ សុខចិត្តធ្វើការស្វ័យទិតៀន អស់លោកនឹងឃើញច្បាស់នូវលទ្ធផលជាក់ស្តែងឥតប្រកែកបានតាមរយៈភស្តុតាងរាប់មិនអស់ ដូចជា រណ្តៅរួមកប់ខ្មោច ដែលមានទូទាំងប្រទេស និងសក្ខីកម្មរបស់ជនរងគ្រោះរាប់មិនអស់ដែរ នៃមហាឧក្រិដ្ឋកម្មរបស់អង្គការបដិវត្តន៍។[13]

ដោយសារតែអង្គការបានប្រកាសខ្លួនឯងថា “អង្គការមានត្រចៀកគ្រប់ទិសទី មានភ្នែកដូចភ្នែកម្នាស់នៅក្នុងប្រទេសកម្ពុជាយើងទាំងមូល”[14] លោក **ពិន យ៉ាថៃ** បាននិយាយថា វាមិនអាចទៅរួចទេ ដែលមេដឹកនាំខ្មែរក្រហមមិនបានដឹងពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ គាត់បានផ្តល់មតិយោបល់ស្នើសុំថា បន្ទាប់ពីពួកគេសារភាព ជនជាប់ចោទគួរតែសុំអភ័យទោសដល់ជនរងគ្រោះទាំងអស់។ យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ការសារភាព និងការសុំអភ័យទោស គឺអាចឲ្យតុលាការនេះធ្វើការបញ្ចប់អាណត្តិរបស់ខ្លួនក្នុងការស្វែងរកការពិត និងភាពយុត្តិធម៌ ដែលបានអូសបន្លាយជាយូរមកហើយនោះ។ ប្រការនេះ ក៏បានជួយឲ្យជនរងគ្រោះបានបញ្ចប់ភារកិច្ចរបស់ខ្លួន ហើយការផ្សះផ្សាជាតិនឹងអាចកើតមានឡើងក្នុងប្រទេសផងដែរ។

នៅខណៈនៃការផ្តល់សក្ខីកម្មរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី មើលទៅហាក់ដូចជាមានទំនុកចិត្ត ហើយទំនងជាមានបំណងប្រាប់ពីការយល់ដឹងរបស់គាត់ស្តីពីអ្វីដែលបានកើតឡើង នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានផ្តល់នូវចម្លើយយ៉ាងវែង ឆ្លើយតបទៅនឹងសំណួរដែលបានសួរគាត់ ភ្លាមៗនោះធ្វើឲ្យភាគីរម្លឹកគាត់ឲ្យសង្ខេបចម្លើយរបស់គាត់។ ក្នុងគោលបំណងស្វែងឡើងយ៉ាងច្បាស់ ដើម្បីគ្រប់គ្រងការឆ្លើយដ៏វែងនេះ សហព្រះរាជអាជ្ញាអន្តរជាតិ **ឃីត រេយ៍ន័រ** (**Mr. Keith Raynor**) បានកាត់បន្ថយរបៀបតាំងសំណួររបស់គាត់ ដោយបែរទៅអានអត្ថបទនៅក្នុងសៀវរបស់លោក **ពិន យ៉ាថៃ** ហើយនិងបានសួរ

ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើការបញ្ជាក់លើអំនាននៃបទដកស្រង់នោះ។ ក្រុមមេធាវីការពារក្តី មិនបានលើកឡើងនូវការជំទាស់ទៅលើការអនុវត្តនេះឡើយ។ មេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** លោក **វ៉ិចទ័រ កូប៉េ** (Mr. Victor Koppe) គ្រាន់តែស្នើសុំសហព្រះរាជអាជ្ញាអន្តរជាតិឲ្យធ្វើការបញ្ជាក់ថា គាត់បានកំពុងស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីបានសរសេរអត្ថបទដកស្រង់ដែលបានអាននេះ ហើយមិនបានទាមទារឲ្យបញ្ជាក់នូវសច្ចភាពរបស់វាឡើយ។ សហព្រះរាជអាជ្ញា **រេយ័ន័រ** បានបញ្ជាក់លើការលើកឡើងនេះ ហើយបានបន្តវិធីសាស្ត្រនៃការតាំងសំណួរនេះ។

## ផ្នែកទី៣ ៖ បញ្ហាច្បាប់ និងនីតិវិធី

ក្រៅតែពីបញ្ហាដែលទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងចូលរួមសវនាការ ហើយនិងប្រភេទនៃសក្ខីកម្មដែលត្រូវបានចម្រាញ់ចេញពីសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី បញ្ហាជុំវិញនៃការបន្តសវនាការលើឯកសារស្តីពីតួនាទីរបស់ជនជាប់ចោទ បានក្លាយជាបញ្ហាផ្លូវច្បាប់ និងបញ្ហានីតិវិធីដ៏សំខាន់នាសប្តាហ៍នេះ។[15] ក្នុងសប្តាហ៍នេះផងដែរ ពុំមានសវនាការលើឯកសារស្តីពីតួនាទីរបស់ជនជាប់ចោទ **នួន ជា** ឡើយ ដោយសារតែគាត់បានមិនមានវត្តមានក្នុងបន្ទប់សវនាការ ហើយគាត់ក៏មិនបានធ្វើការលះបង់សិទ្ធិរបស់គាត់ផងដែរក្នុងចូលរួមតាមដានកិច្ចដំណើរការនីតិវិធីសវនាការ។ ក្នុងចំណោមនោះ ភាគីបានផ្តល់មតិយោបល់លើបញ្ហាមួយចំនួនដូចជា ភាពអាចទទួលយកបាន តម្លៃសាកល្បង និងឯកសារដែលជាប់ពាក់ព័ន្ធដែលបានលើកបង្ហាញដោយខាងការិយាល័យសហព្រះរាជអាជ្ញា ជាពិសេសទៅទៀតនោះ លើសេចក្តីថ្លែងការណ៍របស់សាក្សីដែលបានទទួលមរណភាព។

### ក. សិទ្ធិរបស់ជនជាប់ចោទដើម្បីមានវត្តមានក្នុងការជំនុំជម្រះ

នាសប្តាហ៍នេះ កាលវិភាគត្រូវបានផ្លាស់ប្តូរដើម្បីធ្វើការសង្កេតតាមដានទៅលើសិទ្ធិរបស់ជនជាប់ចោទដើម្បីមានវត្តមានក្នុងការជំនុំជម្រះ។ ជនជាប់ចោទ **នួន ជា** បានកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ហើយបានលុបចោលការលះបង់សិទ្ធិរបស់គាត់ ដើម្បីមានវត្តមានក្នុងអំឡុងពេលនៃសវនាការលើឯកសារដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។ ដូច្នេះ លោកប្រធានអង្គជំនុំជម្រះ **និល ណុន** បានប្រកាសនៅថ្ងៃទី៥ និងថ្ងៃទី៧ ខែកុម្ភៈ ថា ចំពោះផ្នែកនៃសវនាការនេះដែលពាក់ព័ន្ធនឹងករណីរបស់ជនជាប់ចោទ **នួន ជា** ត្រូវបានពន្យារពេល។ សវនាការស្តាប់សក្ខីកម្មរបស់លោក **ពិន យ៉ាថៃ** បានចាប់ផ្តើមនៅថ្ងៃព្រហស្បតិ៍ ដោយសារតែជនជាប់ចោទ **នួន ជា** បានលះបង់សិទ្ធិរបស់គាត់ដើម្បីមានវត្តមានក្នុងសវនាការ នៅខណៈដែលកាលវិភាគសវនាការស្តាប់សក្ខីរបស់សាក្សីដែលមានអត្តលេខ **TCW-100** ត្រូវបានពន្យារពេល ពីព្រោះជនជាប់ចោទរូបនេះ មិនបានផ្តល់ការលះបង់សិទ្ធិដែលពាក់ព័ន្ធនឹងសាក្សីរូបនេះឡើយ។

### ខ. ការជំទាស់ទៅនឹងសំណួរដែលទាញចេញពីគំនិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី

នាសប្តាហ៍នេះ វិវាទកម្មបានកើតមានឡើងសាជាថ្មីម្តងទៀត លើបញ្ហាថា តើសាក្សីដែលមិនមែនជាអ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានគេស្នើសុំឲ្យបញ្ចេញមតិយោបល់របស់ខ្លួន ដើម្បីបន្ថែមលើ

ការផ្តល់សក្ខីកម្មស្តីពីអង្គហេតុ ដែលពួកគេបានឃើញដោយផ្ទាល់ភ្នែកបានដែរឬអត់។ នៅថ្ងៃព្រហស្បតិ៍ មេធាវី **កាណាវ៉ាស** បានស្នើសុំលោក **ពិន យ៉ាថៃ** ឲ្យបញ្ជាក់ពីគំនិត ដែលបានសរសេរនៅក្នុងសៀវភៅរបស់គាត់ថា បរមងាររបស់ **សម្តេច សីហនុ** ជាព្រះបិតាជាតិ គឺជា "ការប្រកាសដោយខ្លួនព្រះអង្គផ្ទាល់"។ មេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោក **គឹម ម៉េងឃី** បានចោទសំណួរពាក់ព័ន្ធនៃរបៀបនៃការតាំងសំណួរនេះ។ មេធាវី **កាណាវ៉ាស** បានពន្យល់ថា គាត់មានបំណងសួរនាំអំពីការអះអាងរបស់លោក **ពិន យ៉ាថៃ** ក្នុងសៀវភៅរបស់គាត់ដែលថា មានប្រជាជនមួយចំនួនបានចូលរួមជាមួយនឹងខ្មែរក្រហម ដោយសារតែស្ថានភាពនៃអំពើពុករលួយ ហើយចំណែកអ្នកដទៃទៀតក៏ធ្វើដូចគ្នាផងដែរ ដោយសារតែឆ្លើយតបតាមការអំពាវនាវឲ្យចូលរួមគាំទ្ររបស់ **សម្តេច សីហនុ** ។ ការជំទាស់នេះ ត្រូវបានច្រានចោល។ ក៏ប៉ុន្តែ មុនពេលដែលដើមបណ្តឹងរដ្ឋប្បវេណី អាចឆ្លើយតប មេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **ពេជ អង្គ** បានធ្វើការជំទាស់ដោយលើកយកមូលហេតុថា ការតាំងសំណួរនេះ កំពុងទាញយកគំនិតដោយផ្ទាល់ចេញពីដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវី **កាណាវ៉ាស** បានបង្ហាញពីការខកចិត្ត ដោយសារតែពេញមួយថ្ងៃនេះ ភាគីដទៃទៀត និងចៅក្រម **ឡាវែន** បានស្នើសុំឲ្យលោក **ពិន យ៉ាថៃ** បង្ហាញគំនិតរបស់គាត់លើបញ្ហាខុសៗគ្នា។ លោកប្រធានអង្គជំនុំជម្រះ បានគាំទ្រការជំទាស់នេះ ដោយបានបញ្ជាក់ថា ការតាំងសំណួររបស់មេធាវី **កាណាវ៉ាស** មិនមានការជាប់ពាក់ព័ន្ធឡើយ។

## គ. ឯកសារដែលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា ស្តីពីតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន

នៅថ្ងៃអង្គារ សហព្រះរាជអាជ្ញាអន្តរជាតិ លោក **ថារីក អាប់ឌុលឡាក់** (Mr. Tarik Abdulhak) បានបន្តបទឧទ្ទេសនាមរបស់គាត់កាលពីសប្តាហ៍មុន ស្តីពីតួនាទីផ្លូវការរបស់ជនជាប់ចោទ **ខៀវ សំផន** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានលើកឡើងពីអត្ថបទដកស្រង់ចេញពីសៀវភៅពីរក្បាល ដែលជនជាប់ចោទបានសរសេរថា៖ "ការពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ" (ដូចដែលហៅបន្តបន្ទាប់មកថា "ការពិចារណា")[16] និង "ប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា ហើយនិងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" (ដូចដែលហៅជាបន្តបន្ទាប់មកថា "ប្រវត្តសាស្ត្រថ្មីៗរបស់កម្ពុជា")[17]។ សៀវភៅទាំងពីរក្បាលនេះ ត្រូវបានលើកយកមកបង្ហាញរួចរាល់ហើយកាលពីសប្តាហ៍មុន ក៏ប៉ុន្តែលោក **អាប់ឌុលឡាក់** បានផ្តោតនៅថ្ងៃអង្គារនេះ ទៅលើផ្នែកដែលបង្ហាញពីការយល់ដឹងរបស់ជនជាប់ចោទ **ខៀវ សំផន** ស្តីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងការកម្ទេចប្រជាជន និងការជម្លៀសប្រជាជនចេញពីទីក្រុង។ លោក **អាប់ឌុលឡាក់** ក៏បានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនូវរបាយការណ៍បទសម្ភាសន៍ចំនួនពីរធ្វើឡើងដោយលោក **ស្ទីវែន ហេដឌើ** (Mr. Steve Heder) ជាមួយជនជាប់ចោទ **អៀង សារី**[18] និងមួយទៀតជាមួយនឹង **តាសុត**[19] ។ សហព្រះរាជអាជ្ញា ក៏បានអានយ៉ាងឮនូវសម្រង់ចេញពីអត្ថបទមួយ ដែលលោក **ប៊ែន឴ឃៀរនិន** (Mr. Ben Kiernan) បានសរសេរតបទៅនឹងសៀវភៅ "ប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា" ។[20] លោក **អាប់ឌុលឡាក់** បានបញ្ចប់បទឧទ្ទេសនាមរបស់គាត់ ដោយបានភ្ជាប់មកជាមួយនឹងសម្រង់វីដេអូខ្លីមួយស្តីពី "**ប៉ុល ពត** និង **ខៀវ សំផន**៖ ការប្រឈមមុននឹងអំពើប្រល័យពូជសាសន៍" (ដូចដែលហៅជាបន្តបន្ទាប់មកថា "**ប៉ុល ពត** និង **ខៀវ សំផន**")[21] ។

### គ.១. ទស្សនវិស័យរបស់ជនជាប់ចោទ ខៀវ សំផន ចំពោះបដិវត្តន៍ និងការគំរាមកំហែងរបស់បរទេសប្រឆាំងនឹងប្រទេសកម្ពុជា

អត្ថបទដកស្រង់ដែលលោក **អាប់ឌុលឡាក់** បានជ្រើសរើសចេញពីសៀវភៅទាំងពីរក្បាលរបស់ជនជាប់ចោទ **ខៀវ សំផន** បានបង្ហាញពីផ្នត់គំនិតរបស់លោក **ខៀវ សំផន** ដែលថា ការស្ថិតនៅក្រោមអំណាចរបស់អាមេរិកាំង ឬវៀតណាម ឬក៏ការគប់គិតនឹងប្រទេសទាំងពីរនេះ បានខិតមកដល់មុនពេល និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសៀវភៅ "ការពិចារណា" គាត់បានពិពណ៌នាពីរបៀបនៃការរំដោះទីក្រុងភ្នំពេញ គឺបានបែកការមុនពេលដែលវៀតណាមរំដោះភាគខាងត្បូងបាន។ ជនជាប់ចោទបានគូសរូបភាពនៃការសង្ស័យប្រទេសជិតខាង ហើយគាត់បានរៀបរាប់ពីភាពចាំបាច់ដើម្បី "អភិវឌ្ឍឲ្យលឿនជាង" ពួកគេ ថ្វីបើនៅក្រោយសម័យរំដោះបានហើយក៏ដោយ។ គាត់បានសំដៅលើការភ័យខ្លាច និងការសង្ស័យនេះ គឺជាមូលដ្ឋាននៃគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរួមបញ្ចូលទាំងការបោសសម្អាតផ្ទៃក្នុង និងសហករណ៍ ដែលបានរៀបរាប់មកហើយក្នុងអត្ថបទដកស្រង់នេះ។ ជនជាប់ចោទរូបនេះ ក៏បានធ្វើការបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ថា ចលនាកម្ពុជាប្រជាធិបតេយ្យ បានដើរតួយ៉ាងសំខាន់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ហើយថា **ប៉ុល ពត** បានធ្វើពលិកម្មដើម្បីការពារអធិបតេយ្យភាពជាតិប្រឆាំងនឹងអាមេរិកាំង និងវៀតណាម។ ជនជាប់ចោទ **ខៀវ សំផន** បានគូសបញ្ជាក់ត្រង់ចំណុចនេះក្នុងវីដេអូស្ដីពី "**ប៉ុល ពត** និង **នួន ជា**" ដែលជនជាប់ចោទរូបនេះនិយាយថា "បើគ្មាន **ប៉ុល ពត** បើគ្មានខ្មែរក្រហមនោះទេ ចាប់តាំងពីសម័យក្រោយរដ្ឋប្រហារឆ្នាំ៧០នោះ កម្ពុជាធ្លាក់ក្នុងកណ្ដាប់ដៃពួកកុម្មុយនីស្តវៀតណាមបាត់ទៅហើយ"។[22]

សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** ក៏បានអានអត្ថបទដកស្រង់ចេញពីសៀវភៅរបស់ជនជាប់ចោទដែលបានពន្យល់ថា ដើម្បីដោះស្រាយបញ្ហាស្បៀងអាហារឲ្យបានគ្រប់គ្រាន់ ការធ្វើទំនើបកម្មវិស័យកសិកម្ម និងការឆ្ពោះទៅរកឧស្សាហូបនីយកម្ម បដិវត្តន៍សង្គមនិយមត្រូវតែយកមកអនុវត្ត ដោយធានាថា បំបាត់កម្មសិទ្ធិឯកជន ហើយយើងគ្រប់គ្នាដាក់ខ្លួនយើងនៅក្នុង "អង្គភាព" នោះដែរ។ ជនជាប់ចោទ បានសំដែងការយល់ឃើញក្នុងសៀវភៅរបស់គាត់ថា "ការបង្ខំ" ត្រូវតែយកមកអនុវត្តនៅដំណាក់កាលដំបូង ដើម្បីប្រកាន់ខ្ជាប់នូវអំណាចរបស់ "រដ្ឋអំណាចដ៏ក្មេងខ្ចី" ហើយដើម្បីធានាថា យើងទាំងអស់គ្នាអាចធ្វើការបានទោះជាក្នុង "ស្ថានភាពដែលយើងខ្វះអ្វីៗទាំងអស់" ក៏ដោយ។

### គ.២. ការយល់ដឹងរបស់ជនជាប់ចោទ អំពីគោលនយោបាយបោសសម្អាតផ្ទៃក្នុង

ក្នុងវីដេអូដែលនិយាយពី "**ប៉ុល ពត** និង **នួន ជា**" ជនជាប់ចោទ **ខៀវ សំផន** បានអះអាងថា គាត់មិនបានដឹងពីអត្ថិភាពនៃមន្ទីរស-២១ ឡើយ។ គាត់បាននិយាយថា គាត់ទើបតែបានដឹងពីមន្ទីរសន្តិសុខនេះតាមរយៈខ្សែវីដេអូមួយ ក្នុងឆ្នាំ១៩៩៨។

ក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា "ការពិចារណា" ជនជាប់ចោទ **ខៀវ សំផន** បានបញ្ចេញគំនិតពីការជឿជាក់ថា "ការអនុវត្តនយោបាយដាច់ខាតនៅក្នុងប្រទេស" គឺមានសារសំខាន់ណាស់ដើម្បីធានាឲ្យបាននូវឯករាជ្យភាពពីប្រទេសវៀតណាមនោះ។ ក្នុងការបដិសេធនូវគំនិតរបស់អ្នកស្រាវជ្រាវ **ហ្វីលីព ស្ស៊ត** ដែលថា ចម្លើយសារភាពនៅមន្ទីរស-២១ ត្រូវបានប្រើប្រាស់សម្រាប់បង្ហាញពីភស្តុតាងនៃអំពើ

ក្បត់ប្រឆាំងនឹងប្រជាជនណាដែលត្រូវបានចាត់ទុកជាគោលដៅរួចហើយតែប៉ុណ្ណោះ។ សៀវភៅរបស់ជនជាប់ចោទ **ខៀវ សំផន** បានចង្អុលបង្ហាញពីការរកឃើញរបស់អ្នកស្រាវជ្រាវរូបនេះថា នៅពេលនោះ វៀតណាមកំពុងចង់បង្កើតចលនាខ្មែររំដោះ។ ជនជាប់ចោទរូបនេះ បានសរសេរថា "នេះបានបញ្ជាក់ថា ការតាមដានរបស់ **ប៉ុល ពត**... ទៅលើ**ចក្រី ឈុក** និង**យ៉ា** ហើយនិងកម្មាភិបាលផ្សេងទៀត ដែលបានរួមជាមួយវៀតមិញ គឺត្រឹមត្រូវ"។[23] ជនជាប់ចោទ **ខៀវ សំផន** បានបំភ្លឺបន្ថែមពីការជឿជាក់ដ៏មុតមាំរបស់គណៈកម្មាការអចិន្ត្រៃយ៍មកលើការវិនិច្ឆ័យរបស់ **ប៉ុល ពត** ទាក់ទិននឹងការអនុវត្តគោលនយោបាយនេះ ដែលមានសរសេរក្នុងសៀវភៅ "ប្រវត្តិសាស្ត្រថ្មីរបស់កម្ពុជា" ដោយបានបញ្ជាក់ថា "**ប៉ុល ពត** ជាមគ្គទេសក៍ ក៏ជាអ្នកប្រវត្តិសាស្ត្រដែលវិភាគ និងសម្រេចមិនចេះខុស" ហើយនៅពេលដែលមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាត្រូវបានចាប់ខ្លួន "គឺមេដឹកនាំម្នាក់ៗជឿជាក់ឥតព្រំដែនមកលើ **ប៉ុល ពត**" ។ ជនជាប់ចោទ បានសរសេរបន្ថែមថា នៅខណៈដែលមានគោលនយោបាយឲ្យដកហូតអង្គរបញ្ជូនមកគណៈមជ្ឈិមបក្ស ដើម្បីបំពេញតាមចំនួនកំណត់ដែលបានសម្រេចទុក បានធ្វើកម្មាភិបាលបក្សជាច្រើននាក់ បាត់បង់នូវភាពស្មោះស្ម័គ្ររបស់ពួកគេទៅនឹងបក្សកុម្មុយនីស្តកម្ពុជា ដូច្នេះវាគឺជាការជ្រៀតជ្រែករបស់វៀតណាម ហើយចុងក្រោយ នៅខែឧសភា ឆ្នាំ១៩៧៦ ការធ្វើអន្តរាគមន៍ពីសំណាក់មេដឹកនាំបក្សកុម្មុយនីស្តវៀតណាម បានជំរុញឲ្យ **ប៉ុល ពត** និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត "ធ្វើការកម្ទេចរនុកក្នុងរបស់វៀតណាម"។

នៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា" ជនជាប់ចោទ **ខៀវ សំផន** ក៏បានលើកឡើងផងដែរពីការចាប់ខ្លួនក្នុងឆ្នាំ១៩៧៨ ហើយនិងការបោសសម្អាតនៅខេត្តព្រះវិហារ។ គាត់បានសរសេរថា គាត់ទើបតែបានឮពីព្រឹត្តិការណ៍មួយថា នៅពេលលេខាបក្សប្រចាំខេត្ត ត្រូវបានចាប់ខ្លួន ហើយជនរងគ្រោះនោះត្រូវបានដោះលែង។ នៅក្នុងសៀវភៅ គាត់បានសរសេរថា គាត់បានគិតថា នៅគ្រានោះ វាជាព្រឹត្តិការណ៍ដែលកើតមានឡើងដាច់ដោយឡែកពីគេតែមួយប៉ុណ្ណោះ។

សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** ក៏បានអានអត្ថបទសម្រង់ចេញពីរបាយការណ៍របស់ **ស្ទីវេន ហេដឌើ** ស្តីពីបទសម្ភាសន៍មួយ ដែលគាត់បានធ្វើជាមួយនឹងជនជាប់ចោទ **អៀង សារី** ។ លោក **ហេដឌើ** បានរាយការណ៍ថា លោក **អៀង សារី** បានអះអាងថា លោក **ខៀវ សំផន** អាចបានឃើញនូវឯកសារទាំងនោះ នៅពេលដែលគាត់ធ្វើជាប្រធានមន្ទីរ ៨៧០។ ជនជាប់ចោទ **អៀង សារី** ក៏បាននិយាយនៅក្នុងបទសម្ភាសន៍ផងដែរថា ទាំងគាត់ និងលោក **ខៀវ សំផន** បានបន្តជឿជាក់ថា "កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលបានចាប់ខ្លួននោះ គឺត្រូវយកទៅរៀនសូត្រ គឺមិនយកទៅសម្លាប់ចោលនោះទេ"។[24] ការដកស្រង់ចេញពីអត្ថបទរបស់លោក **បែន ឃៀរនិន** ក៏បានបញ្ជាក់ផងដែរថា កំណត់ត្រានៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ បានបង្ហាញថា **ខៀវ សំផន** បានមានវត្តមាននៅទីនោះ ពេលដែល **ប៉ុល ពត** បានកំណត់ទិសដៅជាទូទៅ ទៅលើឧត្តមសេនីយ៍ **ចាន់ ចក្រី** ថាជាជនក្បត់។[25]

## *គ.៣. ការជម្លៀសប្រជាជនចេញពីទីក្រុង និងសហករណ៍*

ក្នុងសៀវភៅដែលមានចំណងជើងថា "ការពិចារណា" ជនជាប់ចោទ **ខៀវ សំផន** បានសរសេរថា បញ្ហាសន្តិសុខដែលអាចនឹងកើតមានឡើងក្នុងពេលឆាប់ៗនេះ បានគំរាមកំហែងដល់សន្តិសុខប្រទេសកម្ពុជាដែលបង្ខំឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយគាត់បានអះអាងថា គោលដៅនៃការបង្កើត

សហករណ៍ គឺជាការចាំបាច់បំផុតដើម្បីសម្រេចបាននូវភាពម្ចាស់ការលើស្បៀងដោយខ្លួនឯង។ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុង ជនជាប់ចោទរូបនេះ បានសង្កត់បញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យ គឺជា "រដ្ឋអំណាចដ៏ក្មេងខ្ចី" ហើយមានមនុស្សជាច្រើន "ដែលកំពុងតែផ្ដេតៗចាំតែស្លាប់បន្តបន្ទាប់គ្នានេះ"។ អ្នកទាំងនោះរួមមាន **សេ.អ៊ី.អា** និងពួកកាកសំណល់នៃកងទ័ព **លន់ នល់** ដែលច្បាស់ជានៅមានលាក់អាវុធជាច្រើន នៅកន្លែងផ្សេងៗ ក្នុងប្រទេសកម្ពុជា ជាពិសេសគឺនៅក្នុងទីក្រុងភ្នំពេញ។ គាត់បានធ្វើការអះអាងថា វាអាចនឹងទៅរួច ដែលថា **សេ.អ៊ី.អា** និងបក្សកុម្មុយនីស្តវៀតណាមអាចនឹងចូលដៃគ្នាផ្ដួលរំលំ និងបង្កើតរបបថ្មីមួយទៀត។ ការគំរាមកំហែងទាំងអស់នេះ បានធ្វើឲ្យមានសារសំខាន់បំផុតក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង។ នៅក្នុងសៀវភៅ ជនជាប់ចោទ **ខៀវ សំផន** ក៏បានលើកឡើងពីភាពភ័យខ្លាចចំពោះជ័យជន្នះដ៏លើសលុបរបស់វៀតណាម ដែលជាមូលហេតុនៃការរៀបចំបង្កើតសហករណ៍ឡើង។ កងទ័ពខ្មែរក្រហម ត្រូវតែអាចវាយប្រយុទ្ធដោយឯករាជ្យ "ដើម្បីឲ្យលឿនជាង" កងទ័ពវៀតណាម ហើយការពង្រឹងសហករណ៍ "ធ្វើឲ្យបដិវត្តន៍នៅកម្ពុជាដើរលឿនជាងបដិវត្តន៍នៅចិន កូរ៉េខាងជើង និងវៀតណាម ៣០ឆ្នាំ។

## *គ.៤. តួនាទីរបស់ជនជាប់ចោទក្នុងបក្សកុម្មុយនីស្តកម្ពុជា និងចំណេះដឹងលើគោលនយោបាយរបស់បក្ស*

ក្នុងសៀវភៅ "ការពិចារណា" ជនជាប់ចោទ **ខៀវ សំផន** បានបញ្ជាក់ថា គាត់តែងតែស្រមៃពីប្រទេសកម្ពុជាថា នឹងមានសេដ្ឋកិច្ចឯករាជ្យមួយ ហើយនឹងរួចផុតពី "បុព្វសិទ្ធិ និងអំពើពុករលួយ"។ ក្នុងនាមជាសមាជិកសភាមួយរូប ការបរាជ័យក្នុងការសម្រេចគោលបំណងនេះ បានជម្រុញឲ្យគាត់ចូលរួមជាមួយនឹងខ្មែរក្រហម ដែលកំពុងធ្វើការតស៊ូដើម្បីក្នុងការសម្រេចគោលបំណងដូចគ្នានេះ តាមរយៈវិធីសាស្ត្រខុសៗគ្នា ដោយគាត់បានអះអាងថា គាត់មិនអាចប្រើប្រាស់វាបានឡើយ។ គាត់ក៏បានសរសេរផងដែរថា ការចោទប្រកាន់ដែលថា គាត់បានមកជំនួសកន្លែងរបស់ **ឌឿន** ដែលជាប្រធានកមន្ទីរ ៨៧០ នៅក្រោយពេលដែលគាត់ត្រូវបានគេចាប់ខ្លួន គឺជាការមិនត្រឹមត្រូវទេ។ ជនជាប់ចោទ **ខៀវ សំផន** បានស្ដីបន្ទោសលើការយល់ច្រឡំពីគោលនយោបាយនៃការអនុវត្តដោយសម្ងាត់ ដែលបានអនុវត្តនៅក្នុងពេលនោះថា មានភាពតឹងរ៉ឹងបំផុត សូម្បីតែគាត់ក៏មិនបានដឹងថា **ឌឿន** ត្រូវបានគេចាប់ខ្លួនដែរ។ ក៏ប៉ុន្តែការដកស្រង់មួយចេញពីរបាយការណ៍របស់លោក **ស្ទីវេន ហេដឌើ** ស្ដីពីបទសម្ភាសន៍របស់គាត់ជាមួយនឹងជនជាប់ចោទ **អៀង សារី** បានបង្ហាញពីការយល់ឃើញខុសពីការអះអាងនេះ។ ជនជាប់ចោទ **អៀង សារី** បានប្រកាន់ជំហរថា លោក **ខៀវ សំផន** មានឋានៈនៅក្នុងគណៈមជ្ឈិម ហើយក្រោយមក គាត់ត្រូវបានតែងតាំងជាប្រធានមន្ទីរ ៨៧០ នេះ។

លោក **អាប់ឌុលឡាក់** បានដកស្រង់សារចេញពីសៀវភៅ "ប្រវត្តិសាស្ត្រថ្មីរបស់កម្ពុជា" ដើម្បីបំភ្លឺបន្ថែមទៅលើការជំរុញទឹកចិត្តរបស់ជនជាប់ចោទ ក្នុងការបំពេញតួនាទីរបស់គាត់ជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចំពោះការឡើងឋានៈជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យរបស់គាត់ គឺកើតឡើងបន្ទាប់ពីការលាលែងរបស់សម្ដេច **នរោត្តម សីហនុ**។ ជនជាប់ចោទ **ខៀវ សំផន** បានសរសេរថា គាត់កាន់តំណែងនេះដោយចេញពីកិច្ចការស្នេហាជាតិរបស់គាត់ ក្នុងការរក្សានូវទស្សនៈស្មោះភាពនៃរបបកម្ពុជាប្រជាធិបតេយ្យ និងពង្រឹងភាពខ្លាំងក្លានៅចំពោះមុខវៀតណាម។ សារដែលត្រូវបានអានទាំងនេះ ក៏បានបង្ហាញឲ្យឃើញពីការយល់ដឹងរបស់ជនជាប់ចោទ **ខៀវ សំផន** ស្ដីពីគោលនយោបាយផ្សេង ដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលគាត់បានចូលរួមផងដែរ។[26]

បទសម្ភាសន៍របស់លោក **ស្ទីវេន ហេដឌើ** ជាមួយនឹងសាក្សីដែលបានទទួលមរណភាពទៅហើយនោះ គឺ **តាសុត** ដែលជាអតីតមេបញ្ជាការវរសេនាធំប្រចាំភូមិភាគឧត្តរ បានរៀបរាប់ពីរបៀបដែល **ប៉ង់** ធ្វើជាអ្នកគ្រប់គ្រងនៅ "មន្ទីរ ក" ទាំងអស់ (ដូចជា ក-១ ក-២ ក-៣ ក-៤ ក-៧ និងក-១២) គឺដោយសារទទួលបញ្ជា ភាគច្រើនពី **ប៉ុល ពត** ហើយនិងទទួលបញ្ជារួមពី **ប៉ុល ពត** និងជនជាប់ចោទទាំងបីរូប ក្នុងសំណុំរឿង ០០២នេះ។ **តាសុត** បាននិយាយថា **ប៉ង់** គឺជាប្រធានមន្ទីរ ៨៧០ ហើយបានជួបជាមួយនឹងជនជាប់ចោទ **ខៀវ សំផន** យ៉ាងទៀតទាត់ រហូតដល់មរណភាពរបស់គាត់ក្នុងឆ្នាំ១៩៧៦។ **តាសុត** ក៏បានបញ្ជាក់ផងដែរថា គាត់ធ្លាប់បានចែកសំបុត្ររបស់ **ប៉ុល ពត** និងជនជាប់ចោទទាំងបីនាក់នេះ ទៅឲ្យមេតំបន់នីមួយៗ រួមបញ្ចូលទាំងនៅខេត្តព្រះវិហារផងដែរ។[27]

ឯកសារចុងក្រោយដែលសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានលើកឡើងកាលពីថ្ងៃអង្គារ គឺជាអត្ថបទរបស់លោក **ប៉ែន យៀរនិន** ដែលបានឆ្លើយតបនឹងការអះអាងបដិសេធរបស់ជនជាប់ចោទ **ខៀវ សំផន** ថា មិនបានដឹងឮពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ ការដាក់ឲ្យប្រជាជនរស់នៅជាលក្ខណៈសមូហភាព និងអំពើប្រល័យពូជសាសន៍ ដែលបានកើតមានឡើងនៅពេលដែលគាត់ធ្វើជាប្រមុខរដ្ឋនោះទេ។ ក្នុងការឆ្លើយតបនឹងការបដិសេធរបស់ **ខៀវ សំផន** ជុំវិញតួនាទីជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា លោក **ប៉ែន យៀរនិន** បានចង្អុលបង្ហាញពីកំណត់ហេតុប្រជុំ ដែលបានបង្ហាញថា ជនជាប់ចោទរូបនេះធ្លាប់បានចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ចំនួន១២ដង ក្នុងកិច្ចប្រជុំ១៤លើក នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦។ អ្នកស្រាវជ្រាវរូបនេះ ក៏បានសរសេរផងដែរពីវត្តមាននៃការចូលរួមរបស់ជនជាប់ចោទ **ខៀវ សំផន** ក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដែលបានសម្រេចបង្កើតគណៈកម្មាធិការមួយដែលហៅថា "រដ្ឋាភិបាលសម្ងាត់របស់កម្ពុជា" ដោយមានជនជាប់ចោទមាន "លំដាប់ទីបួន ក្នុងឋានានុក្រម គឺនៅបន្ទាប់ពី **ប៉ុល ពត** លោក **នួន ជា** និងលោក **អៀង សារី**"។

## ឃ. ការផ្តល់មតិយោបល់ពីក្រុមការពារក្តីលើឯកសារ ដែលបានបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា

មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** គឺលោក **អាង ឧត្តម** បានរម្លឹកដល់អង្គជំនុំជម្រះថា ក្រុមការពារក្តីសូមរក្សាសិទ្ធិក្នុងការប្តឹងជំទាស់នៅត្រង់ចំណុចក្រោយមួយនេះ ដែលជាការធ្វើចំណាត់ថ្នាក់នៃឯកសារ ជាជាងផ្តោតទៅលើបញ្ហាបុគ្គលជាក់លាក់។ គាត់ក៏បានបញ្ចេញមតិពីការព្រួយបារម្ភរបស់គាត់ ស្តីពីឯកសារ ដែលបានលើកឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ដែលមិនគ្រាន់តែមិនបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានធ្វើការចោទប្រកាន់អង្គហេតុ ដែលទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនេះផងដែរ។ មេធាវី **អាង ឧត្តម** ក៏បានជំទាស់ទៅនឹងបទឧទ្ទេសនាមស្តីពីកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍សាក្សីដែលបានទទួលមរណភាពទៅហើយនោះ ជាពិសេសគឺសក្ខីកម្មរបស់សាក្សី **តាសុត**។ ក្រុមមេធាវីការពារក្តីបានតវ៉ាថា កំណត់ហេតុនៃបទសម្ភាសន៍ជាមួយនឹងសាក្សីដែលបានទទួលមរណភាព ត្រូវតែដកចេញពីសំណុំរឿងនេះ ពីព្រោះសក្ខីកម្មប្រភេទនេះ មិនអាចឲ្យក្រុមមេធាវីការពារក្តីធ្វើការសាកសួរឆ្លងបានឡើយ។

មេធាវី **ហ្គីសសេ** បានរម្លឹកពីការកត់សម្គាល់ពីមុនរបស់មេធាវី **កូប៉េ** ដែលថា របៀបលក្ខណៈដែលការិយាល័យសហព្រះរាជអាជ្ញាបង្ហាញឯកសារ គឺប្រហាក់ប្រហែលនឹងការស្នើសុំ ជាជាងការបង្ហាញពីការពាក់ព័ន្ធនៃឯកសារ។ លោកស្រីបានបញ្ជាក់ទស្សនៈគាត់ថា ការបង្ហាញឯកសារនៅដំណាក់កាលនីតិវិធីនេះ គឺ "មានការពិបាកណាស់" ហើយគាត់បានរម្លឹកដល់អង្គជំនុំជម្រះពី "ការពិបាក" រវាងការធ្វើបទបង្ហាញឯកសារ និងការបង្កើតការភាន់ច្រឡំ។ បន្ទាប់មក គាត់បានគាំទ្រចំពោះជំហររបស់មេធាវី **អាង ឧត្តម** ទៅលើការខ្វះខាតតម្លៃសាកល្បងក្នុងសេចក្តីថ្លែងការណ៍ និងកំណត់ហេតុដែលពាក់ព័ន្ធនឹងសាក្សីដែលបានទទួលអនិច្ចកម្ម ដោយគាត់បានផ្តល់សេចក្តីថ្លែងការណ៍ជាឧទាហរណ៍មួយ ដែលបានធ្វើឡើងដោយសម្តេចព្រះបរមបិតា ព្រះបាទ **នរោត្តម សីហនុ**។

មេធាវី **ហ្គីសសេ** ក៏បានយល់ស្របនឹងការលើកឡើងរបស់មេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **អេលីហ្សបេត ស៊ីម៉ុនណូហ្វត** (Ms. Elisabet Simonneau Fort) ដែរថា ឯកសារមួយចំនួនមើលយល់យ៉ាងពេញលេញ នៅពេលដែលអ្នកនិពន្ធបានមកធ្វើសក្ខីកម្មក្នុងបន្ទប់សវនាការ។ ការពិចារណានេះ គួរតែមានឥទ្ធិពលលើការសម្រេចកោះហៅសាក្សីក្រោយៗទៀត។ គាត់ក៏បានលើកឡើងផងដែរនូវបញ្ហាឯកសារ ដែលបានសរសេរដោយលោក **ប៉ែន យៀរនិន** ដែលត្រូវបានចាត់ទុកថា ជាភស្តុតាងគន្លឹះក្នុងសំណុំរឿងនេះ ទោះបីជាអ្នកស្រាវជ្រាវរូបនេះ បានបដិសេធមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ ដូច្នេះហើយ វាធ្វើឲ្យក្រុមការពារក្តីមិនអាចចោទសួរដេញដោលលើរូបគាត់បាន។

មេធាវី **ហ្គីសសេ** ដែលបានទទួលជំនួយពីមេធាវីជាតិដៃគូរបស់គាត់ គឺលោកមេធាវី **គង់ សំអុន** បានលើកឡើងជាបន្តបន្ទាប់នូវបញ្ហាលើភាពដែលគួរឲ្យជឿបាននៃឯកសារ ដែលបានបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (**ឌី.ស៊ី.ខេម**)។ ជាឧទាហរណ៍ លោកស្រីបានដកស្រង់ជាពិសេស ទៅលើឯកសារមួយដែលធ្លាប់បានបង្ហាញពីមុនមក ពីសំណាក់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា "អង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជា"។ ជនជាប់ចោទ **ខៀវ សំផន** ត្រូវបានស្គាល់ថាជា "គណៈប្រធានរដ្ឋ" តាមការបកប្រែរបស់ **ឌី.ស៊ី.ខេម** ចំណែកឯឃ្លាឃ្លោងជាភាសាខ្មែរ តាមពិតមានន័យថា "ប្រធានគណៈអធិបតី" ឬ "ប្រធានគណៈប្រតិភូ"។ មេធាវី **ហ្គីសសេ** បានឃើញបញ្ហានេះជាកំហុសដ៏ធ្ងន់ធ្ងរ ពីព្រោះវាបានមួលបង្កាច់ពីតួនាទីរបស់កូនក្តីគាត់ ក្នុងអំឡុងពេលនៃកិច្ចប្រជុំនោះ។ យោងតាមការសាកសួរដេញដោលបន្ថែមពីសំណាក់អង្គជំនុំជម្រះ ដែលធ្វើឡើងដោយចៅក្រម **ឡាវីន៍** មេធាវី **ហ្គីសសេ** បានពន្យល់ថា ប្រធានគណៈប្រធានរដ្ឋ មិនមែនជាអ្នកដែលថ្លែងសុន្ទរកថា ក្នុងអំឡុងពេលនៃអង្គប្រជុំក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជានោះទេ។ មេធាវី **អង់តា ហ្គីសសេ** បានកត់សម្គាល់ថា វាជាភារកិច្ចរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់ថា តើនរណាគេជាអ្នកឡើងថ្លែងសុន្ទរកថា។

## ង. ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្តី

ចំពោះការលើកឡើងនូវការកត់សម្គាល់របស់ក្រុមការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** សហព្រះរាជអាជ្ញាអន្តរជាតិ **វីល្លៀម ស្មីត** បានរម្លឹកដល់អង្គជំនុំជម្រះថា គោលបំណងនៃការសវនាការនាពេលនេះ មិនមែនជាការជជែកតទល់គ្នាលើភាពទទួលយកបាននៃឯកសារ ដែលបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះឡើយ ដូចដែរថា បញ្ហានេះត្រូវបានដោះស្រាយរួចរាល់អស់ហើយ ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

ដែលបានធ្វើឡើងក្នុងខែមិថុនា។ សវនាការនេះ គឺភាគច្រើនសម្រាប់កំណត់នូវតម្លៃសាកល្បងនៃភស្តុតាង។[28] សហព្រះរាជអាជ្ញា ក៏បានរម្លឹកដល់អង្គជំនុំជម្រះផងដែរថា ការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់សាក្សីដែលទទួលអនិច្ចកម្ម គឺត្រូវបានអនុញ្ញាតឲ្យប្រើកាលពីពេលមុនៗ។[29] សហព្រះរាជអាជ្ញា **ស្មីត** បានបញ្ជាក់ថា ភស្តុតាងត្រូវបានលើកយកមកបង្ហាញពីតួនាទីរបស់ជនជាប់ចោទ **អៀង សារី** ជាកិច្ចបន្ថែមពីការកសាងនូវសង្គមនិយមកសិករ ពលករ ឲ្យកើតមានលឿនបំផុត ហើយតាមរយៈការលុបបំបាត់ ឬការសម្លាប់ខ្មាំងនៅខាងក្នុង ឬខាងនៅក្រៅ។ សហព្រះរាជអាជ្ញា **ស្មីត** បានពិនិត្យមើលថា ក្នុងបរិបទនេះ ឯកសារទាំងនេះ មានតម្លៃសាកល្បង ហើយមានជាប់ពាក់ព័ន្ធនឹងសំណុំរឿងមួយនេះផងដែរ។

បន្តមក សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បាននិយាយពីចំណុច ដែលបានលើកឡើងដោយមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន**។ សហព្រះរាជអាជ្ញា បានរម្លឹកដល់អង្គជំនុំជម្រះថា ខាងការិយាល័យសហព្រះរាជអាជ្ញា បានដាក់បញ្ចូលពាក្យស្នើសុំតាមវិធាន៨០ នូវភស្តុតាងឯកសារជាក់លាក់ ដែលបានចងក្រងដោយសម្តេចព្រះបរវបិតា ព្រះបាទ **នរោត្តម សីហនុ** តាំងពីខែសីហា ឆ្នាំ២០១០ មកម្ល៉េះ។ សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** ក៏បានដកស្រង់ឯកសារសម្ងាត់មួយច្បាប់ ដែលហាមឃាត់មិនឲ្យខាងការិយាល័យសហព្រះរាជអាជ្ញា ដាក់ឯកសារទាំងនោះ នៅចំពោះមុខអង្គជំនុំជម្រះតាំងពីដំបូងមក។ ទាក់ទងទៅនឹងឯកសារពាណិជ្ជកម្ម និងជំនួញ ដែលសហព្រះរាជអាជ្ញាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ លោក **អាប់ឌុលឡាក់** បានអះអាងថា ពួកគាត់ត្រូវតែបង្ហាញថា ក្រសួងពាណិជ្ជកម្ម និងជំនួញ បានធ្វើបាយការណ៍ជាបន្តបន្ទាប់មកឲ្យជនជាប់ចោទ **ខៀវ សំផន**។ ប្រការទាំងនេះ បានបង្ហាញថា ជនជាប់ចោទរូបនេះបានដឹងពីអ្វីដែលបានកើតមានឡើងតាមរយៈមូលដ្ឋាននេះ។ ការលើកឡើងពីសក្ខីកម្មរបស់សាក្សី **សគីម លុត**[30] សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានរម្លឹកថា សាក្សីរូបនេះបានផ្តល់សក្ខីកម្មថា លោក **វ៉ាន់ រិត** គឺជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាប់ចោទ **ខៀវ សំផន** និងលោក **វន វ៉េត**។ សហព្រះរាជអាជ្ញា ក៏បានឆ្លើយតបទៅនឹងការជំទាស់ដែលប្រឆាំងនឹងឯកសាររបស់លោក **ប៉ែន យៀរនិន** ។ គាត់បានបញ្ជាក់ថា ថ្វីបើអង្គជំនុំជម្រះសាលាដំបូង បានសម្រេចរួចរាល់ក្នុងការមិនកោះហៅអ្នកជំនាញរូបនេះក៏ដោយ ក៏ប្រការនេះមិនមែនមានន័យថា ឯកសារដែលបានសរសេរដោយលោក **ប៉ែន យៀរនិន** មិនអាចទទួលយកបាននោះដែរ។

ចំពោះបញ្ហាស្តីពីកំហុសនៃការបកប្រែភាសា សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានសន្យាថា ខាងការិយាល័យសហព្រះរាជអាជ្ញានឹងធ្វើការត្រួតពិនិត្យលើកំណត់ហេតុទាំងនេះ។ ក៏ប៉ុន្តែ គាត់ក៏បានធ្វើការស្តីបន្ទោសយ៉ាងចាស់ដៃទៅលើក្រុមមេធាវីការពារក្តី ដោយសារតែពួកគេទើបតែលើកយកមកនិយាយពេលឥឡូវនេះ ខណៈដែលសហព្រះរាជអាជ្ញាបានដាក់បញ្ចូលឯកសារនេះនៅមុខអង្គជំនុំជម្រះអស់រយៈពេលជាងបីឆ្នាំទៅហើយ គឺតាំងពីខែកញ្ញា ឆ្នាំ២០១០ មកម្ល៉េះ។ ដូចអ្វីដែលមេធាវីការពារក្តីបានចង្អុលបង្ហាញ ឯកសារនេះក៏ត្រូវបានយោងក្នុងដីកាដំណោះស្រាយផងដែរ។ សហព្រះរាជអាជ្ញា បានតវ៉ាបន្ថែមថា ខ្លឹមសារនៃសុន្ទរកថាដែលយើងកំពុងជជែកគ្នានេះ គឺដូចគ្នានឹងសុន្ទរកថាផ្សេងៗទៀត ដែលចងក្រងដោយជនជាប់ចោទ **ខៀវ សំផន** នៅក្នុងឯកសារដែលក្រុមការពារក្តីមិនបានជំទាស់នោះទេ។

## ផ្នែកទី៤៖ ការគ្រប់គ្រងសវនាការ

អង្គជំនុំជម្រះ បានបន្តកិច្ចដំណើរការនីតិវិធីសវនាការត្រឹមតែពីរថ្ងៃប៉ុណ្ណោះ ក្នុងសប្តាហ៍នេះ គឺនៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍។ កាលពីថ្ងៃអង្គារ អង្គជំនុំជម្រះបានបិទបញ្ចប់សវនាការលើឯកសារគន្លឹះ ដែលពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ **ខៀវ សំផន** ធ្វើបទបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា។ នៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ពិន យ៉ាថៃ** ដែលមានអត្តលេខសម្គាល់ TCCP-116[31]។

អង្គជំនុំជម្រះ ត្រូវតែធ្វើការកែសម្រួលកាលវិភាគសម្រាប់សប្តាហ៍នេះ ដោយសារតែស្ថានភាពសុខភាពរបស់ជនជាប់ចោទ **នួន ជា** ។ **នួន ជា** ត្រូវបានអនុញ្ញាតជាថ្មីម្តងទៀតឲ្យចូលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យខ្មែរ-សូវៀត នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៣ បន្ទាប់ពីបានចេញពីមន្ទីរពេទ្យនេះកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣។[32]

### ក. វត្តមាន

ជនជាប់ចោទ **អៀង សារី** បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ ខណៈដែលជនជាប់ចោទ **ខៀវ សំផន** មានវត្តមានក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍នេះ។ ជនជាប់ចោទ **នួន ជា** គឺអវត្តមាន ដោយសារតែគាត់ត្រូវទទួលការព្យាបាលនៅឯមន្ទីរពេទ្យ។

***វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី***៖ នៅថ្ងៃអង្គារ មានដើមបណ្តឹងរដ្ឋប្បវេណីប្រមាណជា ១៥នាក់ បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធី។ ក្នុងនោះ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០នាក់បានអង្គុយនៅក្នុងបន្ទប់សវនាការ ចំណែកឯអ្នកផ្សេងទៀតស្ថិតនៅក្នុងសាលសាធារណៈ។ នៅថ្ងៃព្រហស្បតិ៍ មានដើមបណ្តឹងរដ្ឋប្បវេណីច្រើនជាង២០នាក់ បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់សវនាការ និងសាលសាធារណៈ។

***វត្តមានរបស់ភាគី***៖ គ្រប់ភាគីទាំងអស់ មានវត្តមានជាប្រក្រតី នាសប្តាហ៍នេះ ថ្វីបើក្រឡាបញ្ជីបានប្រកាសនៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនៅថ្ងៃព្រហស្បតិ៍នេះក៏ដោយ ក៏មេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោក **ពេជ អង្គ** បានមកដល់យឺតរយៈពេល ២០នាទីផងដែរ។

**វត្តមានរបស់សាធារណជន៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃអង្គារ<br>០៥/០២/២០១៣ | ▪ អ្នកភូមិចំនួន ៣៥០នាក់ មកពីខេត្តចំនួនពីរ គឺខេត្តកំពង់ឆ្នាំង និងកំពង់ធំ<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ៦នាក់ | ពុំមានសវនាការ |
| ថ្ងៃព្រហស្បតិ៍<br>០៧/០២/២០១៣ | ▪ សិស្សានុសិស្សចំនួន ៣៥០នាក់ មកពីវិទ្យាល័យកំពង់ត្របែក ខេត្តព្រៃវែង<br>▪ លោកគ្រូ-អ្នកគ្រូចំនួន ២០នាក់មកពីវិទ្យាល័យកំពង់ត្របែក ខេត្តព្រៃវែង<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ៧នាក់ | ▪ អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ |

## ខ. បញ្ហាបច្ចេកទេស និងការបកប្រែភាសា

នៅថ្ងៃអង្គារ អង្គជំនុំជម្រះ បានបន្តកិច្ចដំណើរការនីតិវិធីយឺត ២០នាទី បន្ទាប់ពីសម្រាកពេលព្រឹក។ លោកប្រធាន **និល ណុន** បានពន្យល់ថា នេះបណ្តាលមកពីឧបករណ៍សម្រាប់ថតមិនដំណើរការ។ បញ្ហាមិនដំណើរការឧបករណ៍នេះ ក៏បានធ្វើឲ្យប៉ះពាល់ដល់ផ្នែកចុងក្រោយនៃការឆ្លើយឆ្លងគ្នារបស់មេធាវី **គង់ សំអុន** ជាមួយនឹងចៅក្រម **ឡាវែន** មុនពេលនៃការសម្រាក ដោយមិនបានធ្វើការថតទុក។ ដូច្នេះ លោកប្រធានអង្គជំនុំជម្រះ បានណែនាំឲ្យមេធាវីការពារក្តីធ្វើការឆ្លើយតបសាជាថ្មីម្តងទៀត។ មានបញ្ហាមួយផ្សេងទៀតទាក់ទងនឹងឧបករណ៍សំឡេង បានកើតមានឡើងកាលពីថ្ងៃព្រហស្បតិ៍ នៅពេលដែលមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **គ្រីស្ទីន ម៉ាទីណូ** (Ms. Chritine Martinau) បានចោទសំណួរទៅកាន់លោក **ពិន យ៉ាថៃ**។ ត្រង់ផ្នែកនេះ ប៉ុស្តិ៍ជាភាសាអង់គ្លេស បានឆ្លងចូលការបកប្រែជាភាសាបារាំងប្រហែលមួយ ឬពីរនាទី ដែលធ្វើឲ្យលោកប្រធាន **និល ណុន** ណែនាំឲ្យមេធាវី **ម៉ាទីណូ** អានសំណួររបស់គាត់ជាថ្មីម្តងទៀត។

## គ. ការគ្រប់គ្រងពេលវេលា

លក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទ **នួន ជា** បានចោទជាបញ្ហាប្រឈមសម្រាប់អង្គជំនុំជម្រះក្នុងការគ្រប់គ្រងកាលវិភាគនៅសប្តាហ៍នេះ និងនៅសប្តាហ៍បន្ទាប់ ដោយសារតែវាអាស្រ័យទៅលើសុខភាពរបស់ជនជាប់ចោទរូបនេះ។ អង្គជំនុំជម្រះ បានប្រកាសថា សវនាការនឹងបន្តនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី **អេលីហ្សាបេត បេកឃើ** (Elizabeth Becker) ដែលមានអត្តលេខ TCW-100[33] ពីព្រោះតែជនជាប់ចោទ **នួន ជា** មិនបានបោះបង់សិទ្ធិរបស់គាត់ដើម្បីមានវត្តមានតាមជានផ្នែកផ្សេងៗទៀតនៃសវនាការលើកស្តុតាងក្នុងសំណុំរឿងនេះឡើយ។ វាបានស្តែងឡើងថា ការសម្រេចនេះ ត្រូវបានធ្វើឡើងតាមការរំពឹងទុកថា ជនជាប់ចោទរូបនេះ នឹងបានជាសះស្បើយឡើងវិញពីជម្ងឺរបស់គាត់ នៅក្នុងរយៈពេលមួយសប្តាហ៍នេះ។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃអង្គារ ០៥/០២/១៣ | ៩:០៥ | ១០:៣២-១១:១៣ | ១១:៣៩ | - | - | ១ម៉ោង និង ៥៣នាទី |
| ថ្ងៃព្រហស្បតិ៍ ០៧/០២/១៣ | ៩:០៤ | ១០:២៩-១០:៤៩ | ១២:០៦-១៣:៣៣ | ១៤:៤៧-១៥:០៥ | ១៥:៥៧ | ៤ម៉ោងនិង ៤៨នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | *៣ម៉ោង និង២០នាទី* | | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | *៦ម៉ោង និង៤១នាទី* | | | |
| *ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* | | | *៦៧១ម៉ោង និង៤២នាទី* | | | |
| ***រយៈពេលសវនាការចំនួន ១៥៤ថ្ងៃ អំឡុងពេល ៤៨សប្តាហ៍*** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Faith Suzzette Delos Reyes, Aviva Nababan, Noyel Ry, and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

1 Trial Chamber. Transcript of Trial Proceedings (7 February 2013). E1/166.1 [hereinafter 7 FEBRUARY TRANSCRIPT]. Lines 14-25. 108.

2 The presentation of documents relating to the roles of the Accused started in the previous week. The presentation of documents relevant to Ieng Sary was completed, while those on Khieu Samphan continued this week. See CASE 002 KRT TRIAL MONITOR. Issue No. 51. Hearing on Evidence Week 46 (28 January-1 February 2013).

3 Pin Yathay was questioned in the following order: President Nil Nonn; National Civil Party Lawyer Kim Mengkhy; International Civil Party Lawyer Christine Martineau; International Prosecutor Keith Raynor; Judge Jean-Marc Lavergne; International Co-Lawyer Ieng Sary, Michael Karnavas; National Co-Lawyer for Khieu Samphan, Kong Sam Onn.

4 7 FEBRUARY Transcript, lines 17-19. 38.

5 Ibid, lines 12-13. 14.

6 Ibid, lines 12-13. 25.

7 Ibid, lines 9-11. 10.

8 Ibid, lines 7-9. 38.

9 Ibid, lines 20-21. 51.

10 Ibid, lines 11-12. 53.

11 Ibid, lines 14-17. 53.

12 Ibid, lines 21-22. 99.

13 Ibid, lines 14-25. 108.

14 Ibid, lines 13-15. 109.

15 See CASE 002 KRT TRIAL MONITOR. Issue 51. Hearing on Evidence Week 46 (28-31 January 2013).

16 Cited by International Prosecutor Abdulhak as Document E/16.

17 Cited by International Prosecutor Abdulhak as Document E/18

18 Cited by International Prosecutor Abdulhak as Document E3/190. Date of the interview was given as 4 January 1999.

19 Cited by International Prosecutor Abdulhak as Document E3/464.

20 Cited by International Prosecutor Abdulhak as Document E3/3512.

21 Cited by International Prosecutor Abdulhak as Document E109/2.3R.

22 The Accused in the same footage also stated also that the involvement of child soldiers in KR forces was driven from the desire to liberate the country and fight for social equality.

23 In the passages quoted by the International Prosecutor Abdulhak, Khieu Samphan also discussed how Pol Pot analyzed Koy Thuon's confessions, which apparently served as the basis for Ya's arrest. Khieu Samphan underlined how the confession revealed that Doeun, the Chairperson of Office 870, passed secret Standing Committee information to Ya, which information was only accessible to Doeun.

24 International Prosecutor Abdulhak also mentioned that the confirmation of Khieu Samphan's elevation to Office 870 could also be found in Document E190.1.72, which was not presented based upon the Trial Chamber's previous directives.

25 Kiernan also wrote that Khieu Samphan always expressed distraught over the purge of Hu Nim, a parliamentarian who was executed on 6 July 1977. However, the Accused went on radio broadcast a day after Hu Nim's arrest, stating "we must wipe out the enemy neatly and thoroughly and suppress all stripes of enemy at all times"

26 Abdulhak quoted passages wherein Khieu Samphan discussed the agenda of the Central Committee's meetings, in particular during the first year. This included discussions to correct faulty agricultural and production practices, starting by equipping the workers with enough farming tools and utilizing some intellectuals to participate in technical education projects. The Prosecutor asserted that this also showed that the CPK's Central Committee managed the conditions and issued directives to the local level.

27 In the excerpts of Steven Heder's report on his interview with Ta Sot, Ta Sot further stated that the "Uncles" also sent letters to regions, districts and villages, but the deceased witness did not deliver those.

28 Anta Guisse, counsel for Khieu Samphan, disagreed with Prosecutor Smith on the purpose of the documentary hearing. She maintained that the objective of the hearing was not to establish the probative value of the documents but their relevance to the case. Probative value, she asserted, could only be debated when the whole body of evidence for the case has been presented.

29 See Trial Chamber. Decision on Co-Prosecutors Rule 92 Submission Regarding the Admission of Witness Statements and Other Documents before the Trial Chamber. 20 June 2012. E 96/7. Para 32, 34. Statements from deceased witness are admissible when their reliability and relevance to the case can be attested, although the probative value of such material is likely limited.

30 See CASE 002 KRT TRIAL MONITOR, Issue 24, Hearing on Evidence Week 19 (28-31 May 2012). 8-11.

31 Trial Chamber. Trial Chamber memorandum entitled "Further information regarding trial scheduling (07 February, 2013)". E236/5. [hereinafter MEMORANDUM ON TRIAL SCHEDULING] para 1, lines 3-5.

[32] MEMORANDUM ON TRIAL SCHEDULING, lines 1-2.

[33] Elizabeth Becker is one of two American journalists allowed by the Khmer Rouge to return to Democratic Kampuchea briefly in 1978. She is the author of When the War Was Over, a book on the modern history of Cambodia and the Khmer Rouge.